ព្រឹត្តិបត្រ ៧ ២០២៤ លេខពិសេស ឆ្នាំទី១៨

# នារីរតនៈ

## NEARY RATTANAK NEWSLETTER




**ពិភពលោក កាន់តែមានសុវត្ថិភាព ស្រស់បំព្រង**

**និងកក់ក្ដៅជាងមុន ប្រសិនបើមានស្ត្រី ក្លាយជាអ្នកដឹកនាំកាន់តែច្រើន**

## អបអរសាទរ
## ខួបលើកទី១១៣
## ទិវាអន្តរជាតិនារី ៨មីនា

ចេញផ្សាយដោយ នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី
info@mowa.gov.kh www.mowa.gov.kh facebook.com/mowa.gov.kh youtube.com/mowacambodiaofficial

## គណៈកម្មការត្រួតពិនិត្យ

លោកជំទាវ ប៊ុន ពុទ្ធី រដ្ឋលេខាធិការ

លោកជំទាវ ថងគៀន ឆ័យម៉ាលី អនុរដ្ឋលេខាធិការ

ឯកឧត្តម ថេ ឈុនហាក់ អគ្គនាយក

## គណៈកម្មការនិពន្ធ និងក្រាហ្វិចកុំព្យូទ័រ

លោកស្រី ប៉ែន គន្ធា

លោកស្រី អ៊ុង ខេមរា

លោកស្រី ប្រាក់ សោភា

លោកស្រី ថា បូណារី

លោក ប៉ោង សុធី

លោក ប៉េង សុធីណា

លោកស្រី តែ សុខខេង

លោកស្រី មាស ពិសី

លោកស្រី ឆយ ឡារី

លោក អ៊ិន បុត្រ

លោក មឿន ឆេង

លោក សឿន វណ្ណារ៉ូ

លោក ហ៊ត ចំរើន

លោក ប៉ែន ជា

កញ្ញា រិទ្ធិ ភារុន

លោក វ៉ន្ត គីមគ័ង


# មាតិកា


-សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះមហាក្សត្រី....................................០១

-ព្រះរាជសារសម្តេចព្រះមហាក្សត្រី....................................................០២

-អនុសាសន៍សំខាន់ៗសម្តេចធិបតី ហ៊ុន ម៉ាណែត..ក្នុងកិច្ចប្រជុំបូកសរុប.....០៥

-សកម្មភាពកាកបាទក្រហមកម្ពុជា.....................................................១០

-អនុសាសន៍សំខាន់ៗរបស់លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ...............១២

-សារ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី គាំទ្របង្កើតកន្លែងថែទាំទារក....១៤

-សារ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត...អបអរសាទរ ....១៦

-វេទិកាថ្នាក់ជាតិ ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច.................១៨

-ឯកសារទស្សនទានយុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ២០២៤..........២៤

-ដំណើរឆ្ពោះទៅមុខក្នុងបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ.............២៦

-អបអរសាទរពិធីខួបលើកទី២៥ នៃការបញ្ចប់សង្គ្រាមស៊ីវិល .....................២៨

-លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី...ដឹកនាំគណប្រតិភូ ចូលរួមកិច្ចប្រជុំ.........៣០

-សន្និសីទភាពជាដៃគូអាស៊ានលើកទី៤ ឆ្នាំ២០២៣.................................៣១

-លោកជំទាវ គ្រី ណាល់លីស៖ បទពិសោធន៍មួយរបស់ស្ត្រី................៣២

-នារីខ្មែរដំបូងជាវិស្វករផ្នែកសម្លេង...................................................៣៣

-អ្នកបង្កើតមាតិកាលើបណ្តាញសង្គម...............................................៣៤

-ពានរង្វាន់ឌីជីថលកម្ពុជា និងពានរង្វាន់ស្ត្រីឆ្នើមក .............................៣៦

-យុវតី អ៊ឹង ហៀកលីញ ពានរង្វាន់ផលិតរ៉ូបូត....................................៣៧

-តារាងស្ថិតិសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ..........៣៩

-ទស្សនៈយល់ដឹងក្រោមមូលបទ«ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តមឌីជីថល..»៤០

-សម្ព័ន្ធភាពរវាងនារី និងកងទ័ព........................................................ ៤២

-ស្ថិតិមន្ត្រីរាជការស៊ីវិលឆ្នាំ២០២៣.......................................................៤៤

# សូមក្រាបបង្គំទូលថ្វាយ
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
# ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព
# សេចក្តីថ្លៃថ្នូរ និង សុភមង្គល



**ក្នុងឱកាសអបអរសាទរខួបលើកទី ១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤**

ខ្ញុំម្ចាស់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជានុញ្ញាតលំឱនកាយ ថ្វាយព្រះសព្ទសាធុការពរ សិរីមង្គល វិបុលសុខ មហាប្រសើរ សូមសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះប្រកបដោយព្រះរាជសុខុមាលភាពល្អបរិបូរណ៍ ព្រះកាយមាំមួន ព្រះទីឃាយុយឺនយូរ ជាងរយព្រះវស្សា ដើម្បីទ្រទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំក្សេមក្សាន្ត សម្រាប់ប្រជានុរាស្ត្រ ទូទាំងព្រះរាជាណាចក្រកម្ពុជា អស់កាលជ័យូរអង្វែងតរៀងទៅ។

**សូមក្រាបបង្គំទូលថ្វាយពី**

**ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងកិច្ចការនារី**

# ព្រះរាជសារ

## សម្ដេចព្រះមហាក្សត្រ នរោត្ដម មុនិនាថ សីហនុ
## ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល
## ក្នុងឱកាសអបអរសាទរខួបលើកទី ១១៣
## ទិវាអន្តរជាតិ នារី ៨មីនា ឆ្នាំ២០២៤

- សូមក្រាបថ្វាយបង្គំសម្ដេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ!
- បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា និងជាទីនឹករឭកដ៏ជ្រាលជ្រៅបំផុត !

នាឱកាសដ៏ល្អវិសេសវិសាលនៃខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤នេះ ក្នុង **ព្រះបរមនាម ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ មានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង សូមថ្វាយនូវសេចក្ដីគោរពសក្ការៈសម្ដេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខ ព្រមទាំងសូមផ្ញើសេចក្ដីនឹករឭកដល់ បង ប្អូន កូនចៅ ចៅទួតទាំងអស់នៅទូទាំងប្រទេស ដែលជានិច្ចកាលតែងតែនឹករឭក គោរពស្រឡាញ់ ផ្ដល់នូវក្ដីស្វាមីភ័ក្ដ និងសេចក្ដីកតញ្ញូដ៏ជ្រាលជ្រៅបំផុតថ្វាយ **ព្រះករុណា ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងរូបខ្ញុំព្រះករុណាផ្ទាល់ ដែលកាយវិការដ៏វិសេសវិសាលនេះ ធ្វើឱ្យខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ ចងចាំ និងគោរពស្រឡាញ់ មិនអាចបំភ្លេចបាន។

ក្នុងទិវាដ៏ថ្លៃថ្លានេះ ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមសម្ដែងនូវការកោតសរសើរ និងសូមគាំទ្រការលើកយកប្រធានបទ «**ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល**» ដែលប្រធានបទនេះ ពិតជាមានសារសំខាន់ និងស្របតាមស្ថានភាពវិវត្តន៍របស់ពិភពលោក និងព្រះរាជាណាចក្រកម្ពុជាយើង។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ បានកត់សម្គាល់ឃើញថា សម្រាប់ព្រះរាជាណាចក្រកម្ពុជា បរិវត្តកម្មឌីជីថល គឺជាការចាំបាច់ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនផលិតភាព ភាពប្រកួតប្រជែង និងប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និងកសាងសង្គមទំនើប ដែលមានពលរដ្ឋមានចំណេះដឹង និងជំនាញខ្ពស់ដែលអាចទទួលបាននូវផលប្រយោជន៍ពីការប្រើប្រាស់សេវាឌីជីថលដោយប្រកាន់ភ្ជាប់នូវមនសិការស្នេហាជាតិ រក្សាបាននូវអត្តសញ្ញាណ និងវប្បធម៌ជាតិ។ បច្ចេកវិទ្យាឌីជីថលដើរតួកាន់តែសំខាន់ក្នុងការសម្រួលដល់ការប្រាស្រ័យទាក់ទង និងផ្សារភ្ជាប់រវាងប្រទេសនិងប្រទេស សង្គមនិងសង្គម

មនុស្សនិងមនុស្ស ព្រមទាំងបង្កើនផលិតភាព និងជំរុញពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ សំដៅជំរុញវឌ្ឍនភាពសេដ្ឋកិច្ចនិងសង្គមជាតិ និងពិភពលោកឱ្យកាន់តែរីកចម្រើនថែមទៀត។

ព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងទទួលភាគផលពីកិច្ចអភិវឌ្ឍលើគ្រប់វិស័យ ក្រោមម្លប់នៃសុខសន្តិភាពពេញលេញបរិបូរណ៍ តាមរយៈការដាក់ចេញនូវនយោបាយ«ឈ្នះ-ឈ្នះ» របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានបញ្ចប់ទាំងស្រុងនូវសង្គ្រាមរ៉ាំរ៉ៃ ធ្វើឱ្យប្រជារាស្ត្រ ជាកូនចៅ ចៅទួត គ្រប់ជាតិសាសន៍បានរស់នៅដោយភាពសុខដុមរមនា ជីវភាពសម្បូរសប្បាយរុងរឿង ថ្កុំថ្កើង គ្មានការរើសអើង មានសិទ្ធិ សេរីភាពពេញលេញក្នុងការគោរពប្រតិបត្តិជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណី។ ទន្ទឹមនឹងនេះ ខ្ញុំ សូមកោតសរសើរ និងអរគុណដល់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលបានដឹកនាំដ៏វាងវៃកម្មវិធីមនុស្សធម៌ និងសកម្មភាពនៅក្នុងវិស័យសុខាភិបាល ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជារាស្ត្រក្នុងគោលបំណងមិនទុកនរណាម្នាក់ឱ្យនៅឯកោ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ជាមួយនិន្នាការសកលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ បូកផ្សំនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ បានជំរុញឱ្យបណ្តាប្រទេសនានាក្នុងពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងនោះ ពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដោយចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលជាកាលានុវត្តភាពមួយដ៏ចម្បង ដើម្បីជំរុញប្រភពកំណើនថ្មីសំដៅឈានទៅសម្រេចបានចក្ខុវិស័យក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការណ៍នេះតម្រូវឱ្យព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំខ្លួនជាស្រេចសម្រាប់ការឆ្លើយតបនឹងការវិវត្តដ៏ឆាប់រហ័សនេះ ក្នុងនោះប្រជារាស្ត្រត្រូវមានចំណេះដឹងផ្នែកឌីជីថល ដើម្បីក្លាយទៅជាពលរដ្ឋឌីជីថល។

រាជរដ្ឋាភិបាលអាណត្តិថ្មី បាននឹងកំពុងខិតខំប្រឹងប្រែងដាក់ចេញនូវគោលនយោបាយ និងវិធានការចាំបាច់ដើម្បីបណ្តុះបណ្តាល និងកសាងមូលធនមនុស្សលើវិស័យឌីជីថល ក្នុងនោះ មាតាបិតា និងអាណាព្យាបាល គឺជាតួអង្គដ៏សំខាន់ ដើម្បីរួមចំណែកក្នុងការតម្រង់ទិសកូនចៅ ជាពិសេសស្ត្រីនិងក្មេងស្រីឱ្យចាប់យកជំនាញបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងសង្គម។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ ខ្ញុំ សូមសម្តែងការកោតសរសើរ និងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយភាពវៃឆ្លាតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួង ស្ថាប័នគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ព្រមទាំងបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ក្នុងដំណាក់កាលទី១ ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព** ដោយផ្តោតលើអាទិភាពគន្លឹះ៥ គឺ **មនុស្ស ផ្លូវ**

**ទឹក ភ្លើង និងបច្ចេកវិទ្យា** ជាពិសេសគឺ **«បច្ចេកវិទ្យាឌីជីថល»** សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មជំនាន់ទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងអំណរព្រះគុណ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមអរគុណដ៏ជ្រាលជ្រៅដល់បងប្អូនជនរួមជាតិ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិទាំងអស់ដែលបាននឹងបន្តខិតខំប្រឹងប្រែងចូលរួមអនុវត្តន៍គោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិថ្មី សំដៅកសាងមូលដ្ឋានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០។

ខ្ញុំ សូមសរសើរ និងគាំទ្រក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបាននឹងកំពុងខិតខំប្រឹងប្រែងអនុវត្តន៍ភារកិច្ចដ៏ថ្លៃថ្លា ដើម្បីស្ត្រី និងក្មេងស្រី បានទទួលនូវកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ តាមរយៈការទទួលស្គាល់ ផ្តល់តម្លៃ និងចាត់ទុកស្ត្រី ក្មេងស្រីជាដៃគូដ៏សំខាន់ ក្នុងការអភិវឌ្ឍន៍គ្រួសារ និងសង្គម ព្រមទាំងជំរុញ លើកទឹកចិត្ត កសាង និងអភិវឌ្ឍន៍សមត្ថភាពស្ត្រីក៏ដូចជាការផ្តល់ឱកាសឱ្យពួកគេចូលរួមប្រកបដោយសមភាព និងសមធម៌ក្នុងគ្រប់ការងារនៅគ្រប់វិស័យ។ ខ្ញុំ សូមអំពាវនាវ និងលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធបន្តយកចិត្តទុកដាក់អនុវត្តន៍ការងារជាបន្តទៀតដើម្បីវិបុលភាព និងសេចក្តីសុខចម្រើនរបស់ជនរួមជាតិយើង ។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ សម្តេចព្រះមហាសង្ឃរាជទាំងពីគណៈ និងប្រគេនពរព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធិពរជ័យ សិរីមង្គលមហាប្រសើរជូនចំពោះថ្នាក់ដឹកនាំ នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ មន្ត្រីរាជការទាំងអស់គ្រប់ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន ព្រមទាំងបងប្អូនរួមជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងនារីទូទាំងសកលលោក សូមបានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ សូមអរគុណ**



# អនុសាសន៍សំខាន់ៗរបស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងកច្ចការនារី រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤




នារសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ក្រសួងកិច្ចការនារី បានរៀបចំពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឱកាសនេះ **សម្តេចធិបតី** បានវាយតម្លៃខ្ពស់ និងកោតសរសើរនូវការងារ និងសមិទ្ធផលដែលសម្រេចបានរបស់ក្រសួងកិច្ចការនារី កន្លងមក។ **សម្តេច**ក៏បានផ្តល់អនុសាសន៍គន្លឹះៗ ដូចខាងក្រោម៖

១. សូមលើកទឹកចិត្តឱ្យក្រសួងកិច្ចការនារី និងក្រសួងស្ថាប័នពាក់ព័ន្ធបន្តវិនិយោគលើស្ត្រី នៅក្នុងក្របខណ្ឌគោលនយោបាយជាតិ និងតាមវិស័យជាប្រព័ន្ធ តាមរយៈការរៀបចំថវិកាឆ្លើយតបយេនឌ័រ និងការអភិវឌ្ឍធនធានមនុស្ស នៅក្នុងក្រសួង-ស្ថាប័ន ។

២. ស្នើឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន សូមបន្តកិច្ចសហការពង្រឹង និងពង្រីកវិធានការគាំទ្រដល់សហគ្រិនស្ត្រី ដែលដឹកនាំសហគ្រាសខ្នាតតូច និងមធ្យម លើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងគ្រប់សកម្មភាពសេដ្ឋកិច្ច និងសង្គម។

៣. ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវពង្រីកវិសាលភាពក្របខ័ណ្ឌជាតិគាំពារសង្គម និងសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល (Universal Health Coverage) សំដៅធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានសេវានេះដោយបរិយាប័ន្ន។

៤. ក្រសួងកិច្ចការនារី ដោយសហការជាមួយក្រសួង-






ស្ថាប័នពាក់ព័ន្ធ ផ្តោតការយកចិត្តទុកដាក់លើការដោះ-ស្រាយគម្លាតយេនឌ័រក្នុងវិស័យឌីជីថល ជាពិសេសការបង្កើនការចូលរួមរបស់ស្ត្រី និងក្មេងស្រី នៅក្នុងវិស័យឌីជីថល ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអប់រំចំណេះដឹង និងជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) ដែលជាវិស័យមានប្រជាប្រិយភាពក្នុងសម័យឌីជីថល ។

**៥.** ដើម្បីលើកកម្ពស់តុល្យភាពជីវិត និង ការងារ (Work-Life Balance) ក្រសួងកិច្ចការនារីត្រូវយកចិត្តទុកដាក់ និង





ធ្វើការសិក្សា ដោយសហការជាមួយដៃគូរដ្ឋ និងឯកជន លើអត្ថប្រយោជន៍សង្គម ដែលទទួលស្គាល់ពីតម្លៃ នៃការងារក្នុងផ្ទះ និងថែទាំសមាជិកគ្រួសារ ព្រមទាំងរៀបចំវិធានការចាំបាច់ ដើម្បីកាត់បន្ថយបន្ទុកលើការងាររបស់ស្ត្រី និងក្មេងស្រី និងផ្តល់ជម្រើស ក្នុងជីវិតរស់នៅកាន់តែច្រើនដល់ស្ត្រី ។

**៦.** ក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងសុខដុមរមនានៅក្នុងគ្រួសារ តាមរយៈការពង្រឹងតួនាទីរបស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ពង្រឹងការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ និងចាត់វិធានការទប់ស្កាត់ និងកាត់បន្ថយហានិភ័យនានា ដែលប៉ះពាល់ដល់សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី និងក្មេងស្រី ។

**៧.** ក្រសួងកិច្ចការនារី និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបន្តអនុវត្តកម្មវិធី និងវិធានការនានា ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិត និងគ្រប់វិស័យ ដើម្បីធានាថាប្រជាជនគ្រប់រូប ទាំងស្ត្រី និងបុរសមានសិទ្ធិ និងឱកាសពេញលេញក្នុងការទទួលបានជម្រើស និងភាពជាតំណាង ក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ប្រកបដោយបរិយាបន្ន និងចីរភាព។

៨. ដើម្បីរក្សាភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារ និងប្រសិទ្ធភាពការងារ ស្នើឱ្យក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ពិនិត្យលទ្ធភាព និងមានវិធានការគោលនយោបាយសមស្រប ដែលអនុញ្ញាតឱ្យស្ត្រីជាអភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ បម្រើការងារមូលដ្ឋានដែលនៅជិតក្រុមគ្រួសាររបស់គាត់ ។

ជាទីបញ្ចប់ **សម្តេចធិបតី** បានស្នើឱ្យក្រសួងកិច្ចការនារីបន្តដឹកនាំសម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការបញ្ចូលនូវអាទិភាពទាំងនេះទៅក្នុងដំណើរការអភិវឌ្ឍ និងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ផែនការយុទ្ធសាស្ត្រនារីរតនៈ និងក្របខណ្ឌគោលនយោបាយ និងកម្មវិធីតាមវិស័យស្របតាមរបៀបវារៈរបស់រាជរដ្ឋាភិបាល ដែលចាត់ទុកការលើកកម្ពស់សមភាពយេនឌ័រ ជាអភិក្រមអាទិភាពស្នូល និងអន្តរវិស័យ៕












សូមចុចយកតាម QR COde
ដើម្បីទទួលឯកសាររបាយការណ៍សង្ខេប
សន្និបាតបូកសរុបលទ្ធផលការងារ
ឆ្នាំ២០២៣ និងលើកទិសដៅការងារ
ឆ្នាំ២០២៤ របស់ក្រសួងកិច្ចការនារី

# សកម្មភាពកាកបាទក្រហមកម្ពុជា




នារាត្រីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២៣ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីលៀងសាយភោជន៍អបអរសេចក្តីថ្លែងការណ៍រាជធានីភ្នំពេញ នៃកិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ និងវេទិកាយុវជនលើកទី២ នៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម តំបន់អាស៊ីអាគ្នេយ៍ ។



# សកម្មភាពកាកបាទក្រហមកម្ពុជា



នាថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២៣ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រារព្ធមហាសន្និបាត កាកបាទក្រហមកម្ពុជាអាណត្តិទី ៧ ដែលប្រព្រឹត្តទៅនៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។



# អនុសាសន៍សំខាន់ៗរបស់លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ប្រធានកិត្តិយស គ.ជ.ស.ស.ខ ថ្លែងក្នុងសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីស្តីការក្រសួងកិច្ចការនារី






**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី** ប្រធានកិត្តិយស គ.ជ.ស.ស.ខ បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងសន្និបាត បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤របស់គ.ជ.ស.ស.ខនៅទីស្តីការក្រសួងកិច្ចការនារី។ សន្និបាតនេះរៀបចំឡើងក្នុងគោល-បំណងដើម្បីរាយការណ៍សង្ខេបអំពីវឌ្ឍនភាពការងារ និងស្នើសុំអនុសាសន៍ណែនាំលើកទិសដៅការងារបន្ត។

**លោកជំទាវបណ្ឌិត**បានផ្តល់នូវអនុសាសន៍គន្លឹះ



សំខាន់ៗដូចខាងក្រោម៖ **ទី១.**បន្តគាំទ្រផែនការយុទ្ធសាស្ត្រនារីរតនៈ ដែលមានគោលបំណងលើកកម្ពស់សមភាពយេនឌ័រ។ ត្រង់ចំណុចនេះ **លោកជំទាវបណ្ឌិត**ក៏ធ្លាប់បានលើកឡើងក្នុងកម្មវិធី បងស្រីនិងប្អូនស្រី កាលពីពេលថ្មីៗនេះថា «នៅក្នុងផ្ទះបើមិនមានភរិយាខ្លាំង មិនមានម្តាយល្អ នោះស្វាមីនិងឪពុកក៏ពិបាកនឹងមានឱកាសគ្រប់គ្រាន់ធ្វើរឿងជោគជ័យនៅខាងក្រៅដែរ» ។

**ទី២.** ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវអនុសាសន៍ទាំង៦របស់**សម្តេចកត្តាព្រឹទ្ធបណ្ឌិត**ជាពិសេសត្រូវគិតគូរចាត់វិធានការចំពោះអនុសាសន៍ និងរាល់ផែនការ

សកម្មភាពទាំងឡាយណាដែលយើងមិនទាន់បានអនុវត្ត។

**ទី៣.** ត្រូវបន្តយកចិត្តទុកដាក់ឱ្យបានជាអតិបរមា ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បញ្ចកោណទី១ មុំទី៥ ស្តីពីការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអរិយធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ត្រង់ចំណុចទី៧ បានចែងបន្តលើកកម្ពស់ការគោរពសីលធម៌ តម្លៃស្ត្រី សេចក្តីថ្លៃថ្នូរក្នុងគ្រួសារ និងសង្គមខ្មែរ រួមទាំងមុំ ដែលមានការពាក់ព័ន្ធដទៃទៀតដែលមានលក្ខណៈជាអន្តរវិស័យ។

**ទី៤.** ត្រូវបន្តតាមដាន និងជំរុញការងារដែលបានដាក់ចេញតាមរយៈគោលនយោបាយ ផែនការសកម្មភាពនានា ដែលក្រសួងកិច្ចការនារីបានរៀបចំកន្លងមក ក្នុងនាមជាសេនាធិការជូនរាជរដ្ឋាភិបាល។ ជាពិសេស យើងត្រូវរួមគ្នាអនុវត្តឱ្យបានម៉ឺងម៉ាត់នូវមាត្រា៣៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ដោយបានកំណត់យ៉ាងច្បាស់អំពីនិយមន័យនៃរូបភាព និងសម្ភារៈ



អាសអាភាស ជាពិសេស ការចែកចាយរូបភាព ឬ ខ្សែវីដេអូ រួមទាំងសម្ភារៈដែលពិពណ៌នាអំពីកេរភេទ ឬភាពអាសអាភាសប្រហាក់ប្រហែល។

**ទី៥.** ត្រូវចូលរួមអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២៤ កន្លងទៅថ្មីៗនេះ៕





# សារ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត
# គាំទ្របង្កើតកន្លែងថែទាំទារកនិងកុមារនៅក្នុងក្រសួង ឬក៏ស្ថាប័ននានា






នាងខ្ញុំសូមគាំទ្រក្នុងការបង្កើតកន្លែងថែទាំទារកនិងកុមារនៅក្នុងក្រសួង ឬក៏ស្ថាបន័នានា ព្រោះម្តាយអាចវិលត្រលប់មក បំពេញការងារបានក្រោយពេលសម្រាកក្រោយសំរាលកូនរួច ហើយម្តាយអាចធ្វើការជូនស្ថាប័នដោយមិនឃ្លាតឆ្ងាយពីកូនតូច




0 1 2 3 4
5 6 7 8 9
10

# សារ លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត
# អបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤









**នៅក្នុងយុគសម័យឌីជីថល បុគ្គលគ្រប់រូបទាំងក្មេងស្រី និងក្មេងប្រុស អាចចាប់យកជំនាញ មុខ-របរនិងការងារនៅក្នុងសង្គមស្របតាមសេចក្តីស្រឡាញ់ សក្តានុពល និងចំណង់ចំណូលចិត្តរបស់ខ្លួន ដោយមិនប្រកាន់ភេទ ឬយេនឌ័រនោះទេ!**

បុគ្គលគ្រប់រូប រួមទាំងក្មេងប្រុស និងក្មេងស្រី មានសិទ្ធិក្នុងការរៀនសូត្រជំនាញ និងជ្រើសរើសមុខរបរសមស្រប តាមសមត្ថភាពរបស់ខ្លួន និងតាមបំណងប្រាថ្នា ដើម្បីចូលរួមអភិវឌ្ឍប្រទេស។ ( និងតម្រូវការរបស់សង្គម )។

នៅក្នុងយុគសម័យឌីជីថល ការចាប់យកចំណេះដឹងឌីជីថល ជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់គ្រប់ៗគ្នាក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាព នៃការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ និងការអភិវឌ្ឍជំនាញ និងមុខរបរ។

មួយវិញទៀត ការចាប់យកជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល គឺជាវិស័យដែលមានប្រជាប្រិយ និងតម្រូវការទីផ្សារការងារខ្ពស់ ហើយកន្លងមកស្ត្រី និងក្មេងស្រីនៅមានចំនួនតិច ដែលបានចូលរួម និងចាប់យកជំនាញនេះ។

ក្នុងឱកាសទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤នេះ យើងទាំងអស់គ្នាលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងក្មេងស្រី ក្នុងវិស័យឌីជីថល ការប្រើប្រាស់បច្ចេកវិទ្យា និងការអប់រំ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ ច្នៃប្រឌិតនិងគណិតវិទ្យា៕

**វេទិកាថ្នាក់ជាតិ ស្ដីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច**
**ក្រោមប្រធានបទ«ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ក្នុងវិស័យនយោបាយនិងសាធារណៈ»**
**ក្រោមអធិបតីភាពសម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភាជាតិ**
**ថ្លែងក្នុង វេទិកាថ្នាក់ជាតិ ស្ដីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច**











ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
លេខ..........✓.............. កកន

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលសង្ខេបវេទិកាជាតិ ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច
# បានរៀបចំថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**វេទិកាថ្នាក់ជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច** គឺជាព្រឹត្តិការណ៍ជាតិប្រចាំឆ្នាំ ដែលបានចាប់ផ្តើមរៀបចំតាំងពីឆ្នាំ២០២២ ដោយមានការចូលរួមពីស្ត្រីជាថ្នាក់ដឹកនាំគ្រប់កម្រិតនិងដៃគូពាក់ព័ន្ធ ដើម្បីពិភាក្សានិងចែករំលែកមេរៀនបទពិសោធន៍ និងកំណត់រកកាលានុវត្តភាពនៅក្នុងការចូលរួមចំណែកលើកកម្ពស់តួនាទីស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច ។

នៅក្នុងឆ្នាំ២០២៣នេះ ក្រសួងកិច្ចការនារីបានរៀបចំ**វេទិកាថ្នាក់ជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច** ក្រោមប្រធានបទ**«ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេចក្នុងវិស័យ នយោបាយនិងសាធារណៈ»** ក្នុងគោលបំណងជំរុញការចូលរួមរបស់ស្ត្រី នៅក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ទាំងនៅក្នុងវិស័យនយោបាយនិងសាធារណៈ ជាពិសេសក្នុងបរិបទបរិវត្តកម្មឌីជីថល និងរដ្ឋាភិបាលឌីជីថល។

វេទិកានេះ បានរៀបចំឡើងនា**ថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ រាជធានីភ្នំពេញ** ដែលទទួលបាន**កិត្តិយសដ៏ឧត្តុង្គឧត្តម** ពី**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** អញ្ជើញចូលរួមជាអធិបតី និងផ្តល់នូវសុន្ទរកថាគន្លឹះក្នុងពិធីបើកវេទិកា និងដោយមានការចូលរួមពីសំណាក់សមាជិកព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល តំណាងមកពីក្រសួង-ស្ថាប័ន អង្គទូត ប្រធាន-សមាជិកក្រុមប្រឹក្សានិងអភិបាល-អភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ប្រធាន-សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អ្នកស្រាវជ្រាវ វិស័យឯកជន និងតំណាងយុវជនមកពីសាកលវិទ្យាល័យនានា ព្រមទាំងដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល ដែលចូលរួមដោយផ្ទាល់ ចំនួន៣០០រូប និងតាមប្រព័ន្ធអនឡាញ ចំនួន១ ៥៨៦រូប ដែលសរុប ចំនួន១ ៨៨៦រូប ។

**លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី** បានលើកឡើងថា វេទិកាជាតិដ៏សំខាន់ក្នុងឆ្នាំនេះរៀបចំឡើងស្របតាមការចង្អុលបង្ហាញនៅក្នុង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**



ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៧

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលរាជរដ្ឋាភិបាលបានកំណត់**ការលើកកម្ពស់សមភាពយេនឌ័រនិងការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីនៅគ្រប់វិស័យ** ជាអាទិភាពនៅក្នុងរបៀបវារៈ**គោលនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** តាមរយៈការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាប័ន្ន ដែលក្នុងនោះ ស្ត្រីគឺជាស្នូល។ រាជរដ្ឋាភិបាល នឹងជំរុញការចូលរួមរបស់យុវតី ក្នុងការកំណត់ជោគវាសនារបស់ប្រទេសជាតិ និងបង្កើនឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិស្សនិងនិស្សិតនារី តាមរយៈការបង្កើនអាហារូបករណ៍ និងកម្មវិធីបំប៉ន នៅតាមគ្រឹះស្ថានសិក្សា ការផ្តល់កន្លែងស្នាក់នៅ ការធានាសុវត្ថិភាព និងការបង្កើនចំនួនគ្រូបង្រៀនជាស្ត្រី ការបង្កើនសមាមាត្រនៃការចូលរួមស្ត្រីឱ្យបានជាអតិបរមានៅក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ការពង្រឹងឱកាសការងារ និងការពារសិទ្ធិធ្វើការងាររបស់ស្ត្រី ព្រមទាំងបន្តការតម្លើងតួនាទីរបស់ស្ត្រី នៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតជាដើម។

នៅក្នុងវិស័យសាធារណៈនិងនយោបាយ បច្ចុប្បន្ន កម្ពុជាមានស្ត្រីជាប្រធានរដ្ឋសភា ស្ត្រី១៧រូបជាសមាជិការដ្ឋសភា និង ២រូបជាប្រធានគណៈកម្មការជំនាញ។ ស្ត្រីជាអគ្គទេសាភិបាលធនាគារជាតិ ស្ត្រីជាអគ្គសវនករជាតិ ស្ត្រីជារដ្ឋមន្ត្រី ៣រូប មន្ត្រីរាជការជាស្ត្រី មាន៤២% និង២៧% ដែលស្ត្រីមន្ត្រីរាជការមានតួនាទីនៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ស្ត្រីជាអភិបាលខេត្ត២រូប ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ ៦រូប ហើយស្ត្រី ជាមេឃុំ-ចៅសង្កាត់ ១៧៦រូប ។ ការរីកចម្រើននៅក្នុងការលើកកម្ពស់តួនាទីស្ត្រីនៅក្នុងវិស័យសាធារណៈកន្លងមក អាស្រ័យដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ពីរដ្ឋសភាជាតិ និងដៃគូពាក់ព័ន្ធ ដែលបានណែនាំឱ្យមានការគិតគូរបញ្ចូលឱ្យមានស្ត្រី នៅគ្រប់ប្រអប់តួនាទីធ្វើសេចក្តីសម្រេច ក្នុងក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងនៅក្នុងរដ្ឋបាលឃុំ-សង្កាត់ និងតាមភូមិ និងការជ្រើសរើសមន្ត្រីមុខងារសាធារណៈថ្មី ត្រូវមានស្ត្រីចាប់ពី២០%ទៅ៥០%។ ក្រសួង-ស្ថាប័ន បានរៀបចំយន្តការ និងក្រុមការងារយេនឌ័រនៅតាមវិស័យនិងនៅថ្នាក់ក្រោមជាតិ ព្រមទាំងបញ្ចូលកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងស្ថាប័ន និងដែនរដ្ឋបាលរបស់ខ្លួននីមួយៗ។

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា**បានកោតសរសើរនិងគាំទ្រដល់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងដែលនៅក្នុងយុទ្ធសាស្ត្រនេះ បានបញ្ជាក់យ៉ាងច្បាស់ពីការបន្តយកចិត្តទុកដាក់លើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ។ **សម្តេចមហារដ្ឋសភាធិការធិបតី** ក៏បានគូសបញ្ជាក់ពីវឌ្ឍនភាពនិងគុណតម្លៃនានា រួមទាំងការគាំទ្ររបស់

ស្ថាប័ននីតិបញ្ញត្តិ រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅគ្រប់កម្រិត។

កន្លងមក **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានលើកឡើងថា «**ពិភពលោកនឹងកាន់តែសុវត្ថិភាព ស្រស់បំព្រងនិងកក់ក្តៅជាងមុន ប្រសិនបើមានស្ត្រីក្លាយជាអ្នកដឹកនាំកាន់តែច្រើន**»។ **សម្តេចមហារដ្ឋសភាធិការធិបតី** បានបញ្ជាក់ថា នេះជាសារដ៏មានអត្ថន័យ និងបានបង្ហាញច្បាស់ពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងរយៈពេលមួយថ្ងៃ អង្គវេទិកាបានពិភាក្សា និងចែករំលែកមេរៀនបទពិសោធន៍ និងទស្សនៈក្នុងការរួមចំណែកដើម្បីថែរក្សាសុខសន្តិភាព និងកិច្ចអភិវឌ្ឍគ្រប់វិស័យ តាមរយៈការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ខ្លួន ។ អង្គវេទិកាក៏ទទួលបានមតិយោបល់ និងធាតុចូលសំខាន់ៗពីអ្នកជំនាញ តំណាងស្ត្រីជាអ្នកដឹកនាំនិងដៃគូពាក់ព័ន្ធ ដើម្បីជាចំណែកក្នុងការជំរុញនិងស្វែងរកការគាំទ្រពីសំណាក់ស្ថាប័ន និងដៃគូពាក់ព័ន្ធលើការលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅគ្រប់កម្រិត។ បណ្តាញទំនាក់ទំនងស្ត្រីជាអ្នកដឹកនាំ បានពង្រឹង និងពង្រីក ព្រមទាំងផ្តល់នូវភាពជាគំរូរបស់ស្ត្រីជាអ្នកដឹកនាំ ក្នុងការបណ្តុះសន្ទុះចិត្ត (inspire) ដល់ស្ត្រីនិងក្មេងស្រី ឱ្យចូលរួមកាន់តែសកម្ម ប្រកបដោយសក្តានុពលនិងពេញលេញនៅក្នុងកិច្ចអភិវឌ្ឍ។

អង្គវេទិកា បានលើកឡើងថា ចំណុចខ្លាំង និងកត្តាដែលជំរុញឱ្យស្ត្រីជាអ្នកដឹកនាំបានចូលរួមចំណែកក្នុងការបង្កើតឱ្យមាននូវសមិទ្ធផលសំខាន់ៗ អាស្រ័យដោយមានការគាំទ្រ និងលើកទឹកចិត្តជានិច្ចជាកាលពីសំណាក់ប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំស្ថាប័ន-អង្គភាព គណបក្សនយោបាយ ដៃគូពាក់-ព័ន្ធ សហគមន៍ និងក្រុមគ្រួសារ ព្រមទាំងការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងផ្ទាល់របស់ស្ត្រីលើភាពជាអ្នកដឹកនាំ បង្កើតភាពជាគំរូ រួមទាំងការអភិវឌ្ឍសមត្ថភាព បទពិសោធន៍និងអាកប្បកិរិយារបស់ខ្លួនប្រកបដោយភាពធន់ខ្ពស់។ សម្ព័ន្ធភាព និងបណ្តាញស្ត្រីជាអ្នកដឹកនាំនៅគ្រប់កម្រិតនិងគ្រប់មជ្ឈដ្ឋាន គឺជាកម្លាំងនិងស្មារតីរួម ដើម្បីលើកទឹកចិត្តនិងគាំទ្រគ្នាទៅវិញទៅមក ក្នុងការបំពេញការងារប្រកបដោយថាមពល និងដោយផ្អែកតាមចំណុចឧត្តមានុវត្ត និងភាពខ្លាំងរបស់ខ្លួនម្នាក់ៗ។

បញ្ហាប្រឈម និងតម្រូវការឱ្យយកចិត្តទុកដាក់បន្ថែមទៀត រួមមាន៖ តម្រូវការឱ្យមានការគាំទ្រពីក្រុមគ្រួសារ ក្នុងការចែករំលែកការទទួលខុសត្រូវលើបន្ទុកការងារផ្ទះ ការងារមើលថែទាំសមាជិកក្រុមគ្រួសារ និងកូនៗ ស្ត្រីនិងក្មេងស្រីមានតម្រូវការក្នុងការបង្កើនទំនុកចិត្ត និងភាពជឿជាក់លើខ្លួនឯងពង្រឹងកិច្ចសហការ និងគាំទ្រដល់ស្ត្រីជាថ្នាក់ដឹកនាំ ការបង្កើនការយល់ដឹង និងគាំទ្រពីតម្លៃនៃការចូលរួមរបស់ស្ត្រី ជាពិសេសក្នុងវិស័យសាធារណៈ និងនយោបាយនៅមានកម្រិតនៅឡើយ។

អនុសាសន៍ និងមតិយោបល់របស់អង្គវេទិកា មានដូចខាងក្រោម៖

១. សុខសន្តិភាព នៅតែជាមូលដ្ឋានគ្រឹះនៃកិច្ចអភិវឌ្ឍ ហើយជាកាលានុវត្តភាពដើម្បីអភិវឌ្ឍ និងអនុវត្តគោលនយោបាយសមភាពយេនឌ័រនៅគ្រប់វិស័យ។ នៅក្នុងបរិបទនេះ តម្រូវឱ្យគ្រួសារនិងសង្គមទាំងមូលស្វែងយល់ពីការវិវត្តរបស់សង្គមនិងបន្តជំរុញឱ្យស្ត្រីនិងក្មេងស្រី ទទួលបានការអប់រំ ការអភិវឌ្ឍជំនាញ (រួមមានជំនាញទន់ ជំនាញរឹង និងជំនាញឌីជីថល និង STEAM) និងនៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេចប្រកបដោយសមធម៌និងសមភាព ដើម្បីធានាថា *«មិនទុកនរណាម្នាក់ឱ្យនៅឯកោ»* ជាពិសេសស្ត្រីនិងក្មេងស្រីឱ្យនៅក្រៅសំណាញ់នៃកិច្ចអភិវឌ្ឍ។

២. ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច ទាមទារឱ្យមានការគិតគូរជាប្រព័ន្ធនិងឱ្យបានគ្រប់ជ្រុងជ្រោយ ដែលតម្រូវឱ្យមានការចូលរួមនិងទទួលខុសត្រូវពីគ្រប់ដៃគូពាក់ព័ន្ធ និងថ្នាក់ដឹកនាំនៅគ្រប់កម្រិត តាមរយៈការដាក់ចេញនូវគោលនយោបាយ និងវិធានការពិសេសជាក់លាក់ផ្តល់ធនធានសមស្រប ក៏ដូចជាការបញ្ជ្រាបយេនឌ័រនៅតាមវិស័យនិងគ្រប់កម្រិត។

៣. ភាពជាគំរូ និងការចងក្រងបណ្តាញស្ត្រីជាអ្នកដឹកនាំ ព្រមទាំងប្រព័ន្ធផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព និងហ្វឹកហ្វឺនក្នុងភាពជាអ្នកដឹកនាំ គឺជាកត្តាចាំបាច់ ខណៈស្ត្រីនិងក្មេងស្រី ត្រូវចាប់យកឱកាសនិងបណ្តុះភាពជាអ្នកដឹកនាំរបស់ខ្លួនឯង ដោយផ្អែកលើសក្តានុពល និងទេពកោសល្យរបស់ខ្លួននីមួយៗ។

៤. ស្ត្រីនិងក្មេងស្រី ត្រូវការការគាំទ្រ និងការចែករំលែកលើការទទួលខុសត្រូវ ចំពោះការងារថែទាំនៅផ្ទះនិងគ្រួសារ ពង្រឹងនិងពង្រីកបរិយាកាសមេត្រីភាពនិងសុវត្ថិភាពនៅកន្លែងធ្វើការនិងនៅសហគមន៍ដូចជាទារកដ្ឋានជាដើម ដែលជាចំណែកមួយជួយគាំទ្រដល់ស្ត្រី ក្នុងការចូលរួមក្នុងភាពជាអ្នកដឹកនាំនិងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមបានពេញលេញ។

៥. ចំពោះវិស័យសាធារណៈ ការធ្វើបរិវត្តកម្មឌីជីថល និងនៅក្នុងរបៀបវារៈថ្មីៗនានា ការគិតគូរនិងឆ្លើយតបនឹងសមភាពយេនឌ័រ ដែលជាកត្តាចាំបាច់និងធានាថាវឌ្ឍនភាពកន្លងមកនៅតែបន្ត និងកាលានុវត្តភាពថ្មី ត្រូវបានប្រើប្រាស់ដើម្បីជួយជំរុញការអនុវត្តមុខងាររបស់ក្រសួង-ស្ថាប័ន ក្នុងការលើកតួនាទីស្ត្រីក្នុងរដ្ឋាភិបាលឌីជីថល ប្រកបដោយបរិយាបន្ន និងសមធម៌។

៦. ជំរុញ និងលើកកម្ពស់ការយល់ដឹង និងពិគ្រោះយោបល់ផ្អែកគោលនយោបាយពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងដំណើរការរៀបចំនិងអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសលើកិច្ចការរៀបចំប្រព័ន្ធជ្រើសរើសមន្ត្រីរាជការ ការលើកកម្ពស់សមិទ្ធកម្មការងារ និងប្រព័ន្ធលើកទឹកចិត្តមន្ត្រីរាជការ ដោយផ្សារភ្ជាប់ជាមួយនឹងការពិចារណា និងឆ្លើយតបលើការលើកកម្ពស់សមភាពយេនឌ័រ ។

4

ក្រសួងកិច្ចការនារី និងអង្គវេទិកាទាំងមូល សំណូមពរឱ្យក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងដៃគូពាក់ព័ន្ធទាំងអស់ រួមទាំងកម្រិតគ្រួសារចូលរួមក្នុងការបន្តជំរុញការអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ នៅគ្រប់កម្រិតនិងគ្រប់មជ្ឈដ្ឋាន ។

អង្គវេទិកា នឹងប្រើប្រាស់អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្ដេចមហារដ្ឋសភាធិការធិបតី** រួមទាំងលទ្ធផលនៃអង្គវេទិកាឆ្នាំ២០២៣នេះ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលកម្ពុជា ចែករំលែកជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីបញ្ជ្រាបក្នុងក្របខណ្ឌគោលនយោបាយនិងដាក់ចេញនូវវិធានការជាក់លាក់ និងរៀបចំកម្មវិធីនានា ដើម្បីបន្តឈានឆ្ពោះទៅលើកកម្ពស់សមភាពយេនឌ័រនិងការចូលរួមរបស់ស្ត្រី ដោយពេញលេញ និងប្រសេកម្មនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច និងអភិបាលកិច្ចនៅគ្រប់កម្រិត និងគ្រប់វិស័យជាបន្តបន្ទាប់បន្ថែមទៀត។ លទ្ធផលទាំងនេះនឹងក្លាយជាធាតុចូលសម្រាប់យកទៅពិគ្រោះយោបល់នៅក្នុងដំណើរការរៀបចំ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ២០២៤-២០២៨** ។

អង្គវេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច នឹងបន្តរៀបចំនៅឆ្នាំ២០២៤ ដែលជាយុទ្ធនាការប្រចាំឆ្នាំ ក្នុងការស្វែងរកការគាំទ្រពីសំណាក់ស្ថាប័ននិងដៃគូពាក់ព័ន្ធ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងដើម្បីពង្រឹងបណ្តាញស្ត្រីជាអ្នកដឹកនាំ បណ្តុះសន្ទុះចិត្តដល់ស្ត្រីនិងក្មេងស្រីឱ្យចូលរួមប្រកបដោយសក្តានុពល និងពេញលេញនៅក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត ។

ថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានី ភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣



# ឯកសារទស្សនទាន

## យុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣
## ក្រោមមូលបទ «ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល »

"Women and Girls in Digital Transformation"



យុទ្ធនាការទិវាអន្តរជាតិនារី៨មីនាគឺជាព្រឹត្តិការណ៍ជាសកល ដែលមហាសន្និបាតអង្គការសហប្រជាជាតិ បានប្រកាសជាទិវារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិស្ត្រី និងសន្តិភាពពិភពលោកនាឆ្នាំ១៩៧៧។ ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជា បានរៀបចំយុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ដើម្បីរំលឹកពីការតស៊ូទាមទារសិទ្ធិស្មើគ្នា សេរីភាព និងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព សមិទ្ធផល បញ្ហាប្រឈម ការប្តេជ្ញាចិត្ត និងវិធានការជាវិជ្ជមាននានា នៅក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប។

ក្នុងឆ្នាំ២០២៤នេះ ក្រសួងកិច្ចការនារី ក្នុងកិច្ចសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន រួមទាំងបណ្តាញផ្សព្វផ្សាយ បានរៀបចំយុទ្ធនាការ អបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា



ខួបទី១១៣ ក្រោមមូលបទ «*ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្ម-ឌីជីថល*» ក្នុងគោលបំណងរំលេចអំពីសក្តានុពល និងភាពចាំបាច់នៃការលើកកម្ពស់ការចូលរួមនិងភាពជាតំណាងរបស់ស្ត្រី និងក្មេងស្រី ក្នុងវិស័យឌីជីថល ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។

ការកំណត់មូលបទសម្រាប់យុទ្ធនាការឆ្នាំនេះរបស់កម្ពុជាបានរៀបចំឡើងឆ្លើយតបនឹងបរិបទ នៃការវិវត្តរបស់សង្គមក្នុងយុគសម័យឌីជីថល និងស្របតាមចក្ខុវិស័យដែលបានចង្អុលបង្ហាញនៅក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា និងក្របខណ្ឌគោលនយោបាយក្នុងការលើកកម្ពស់ សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី។

នៅក្នុងយុទ្ធនាការនេះ បានដំណើរការទៅចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ ដោយមានព្រះរាជសាររបស់**សម្តេចព្រះមហាក្សត្រ នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងសារលិខិតអបអរសាទររបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន និងបណ្តាញសង្គមផ្លូវការរបស់រដ្ឋនានា ជាពិសេសដើម្បីកៀរគរដល់ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូប ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី ក្នុងយុគសម័យឌីជីថល ដើម្បីឈានទៅរកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។

នៅក្នុងនោះ ក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធបានរៀបចំសកម្មភាពសំខាន់ៗដូចខាងក្រោម៖

+ គណៈប្រតិភូនារីចូលជួបសំដែងការគួរសម និងរាយការណ៍វឌ្ឍនភាពនៃការងារនារីជូន**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។
+ រៀបចំវេទិកាយុវជនដើម្បីផ្សព្វផ្សាយតាមទូរទស្សន៍ និងយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល។
+ រៀបចំពិធីអបអរសាទរខួបទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ នៅតាមក្រសួង-ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។
+ រៀបចំផលិតវីដេអូឯកសារដើម្បីផ្សព្វផ្សាយតាមទូរទស្សន៍ និងផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល និងចងបដាពាក្យស្លោកតាមមហាវិថីនានា។
+ ផលិត និងផ្សព្វផ្សាយសារ និងវីដេអូខ្លីៗរបស់ថ្នាក់ដឹកនាំជាស្ត្រី សិល្បការិនី អ្នកដែលមានឥទ្ធិពលក្នុងបណ្តាញសង្គម (Influencers) ជាស្ត្រី យុវជន និងក្មេងស្រី នៅក្នុងបណ្តាញផ្សព្វផ្សាយឌីជីថល។
+ ផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រនារីរតនៈលេខពិសេស ក្រោមមូលបទ«ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្ម-ឌីជីថល»។



# ដំណើរឆ្ពោះទៅមុខក្នុងការបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ (Marching Zero GBV and Advancing Gender Equality)




ក្រសួងកិច្ចការនារី និងអង្គការUNFPA បានសហការផ្តួចផ្តើមឱ្យមានគម្រោងនវានុវត្តន៍ថ្មី ដោយផ្សារភ្ជាប់ទៅនឹងគោលគំនិតដើមនៃឯកសារទស្សនទានដំណើរឆ្ពោះទៅមុខក្នុងការបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ (Marching Zero GBV and Advancing Gender Equality) ក៏ដូចជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងសន្និសីទ ICPD នាទីក្រុងណៃរ៉ូប៊ីកា។ គម្រោងថ្មីនេះ បានប្រើប្រាស់នូវឯកសារពិគ្រោះ៖ លទ្ធផលនៃការពិនិត្យពាក់កណ្តាលអាណត្តិរបស់ UNFPA និងទិន្នន័យចម្បងពីការសិក្សាស្រាវជ្រាវ VAW Big Data និងការស្រាវជ្រាវផ្សេងទៀតដែលបានបង្ហាញថា មានការកើនឡើងនៃអំពើហិង្សាលើស្ត្រី និងកុមារអំឡុងពេលជំងឺរាតត្បាត COVID-19។ ការឯកភាពរួមគ្នាក្នុងការស្វែងរកការគាំទ្រទៅលើគម្រោងនេះ ជាពិសេសសសរស្តម្ភទី៥ "**ការទប់ស្កាត់ GBV តាមរយៈការផ្លាស់ប្តូរបទដ្ឋាន និងអាកប្បកិរិយាសង្គមដែលរួមបញ្ចូលនូវសមធម៌យេនឌ័រ**" គឺការអន្តរាគមន៍ទៅលើឌីជីថល៖ ការធ្វើនវានុវត្តន៍សម្រាប់ការចែករំលែកព័ត៌មាន ដើម្បីផ្លាស់ប្តូរអកប្បកិរិយា និងបទដ្ឋានសង្គម រួមទាំងទំនាក់ទំនងនៅ ក្នុងដំណើរការបញ្ជូន ជនរងគ្រោះ។

គម្រោងដែលផ្តួចផ្តើមឱ្យមានការផ្តល់ព័ត៌មានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទតាមរយៈប្រព័ន្ធឌីជីថល រួមមានកម្មវិធីទូរស័ព្ទដៃ (Mobile App) និង Chatbot នៅក្នុងប្រអប់សារនៃប្រព័ន្ធហ្វេសបុក របស់ក្រសួងកិច្ចការនារីត្រូវបាននវានុវត្តន៍ ដោយមានការគាំទ្រពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) រាជរដ្ឋាភិបាលជប៉ុន និងមូលនិធិ Wesley Foundation។ ឧបករណ៍ បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន (ICT) ដែលមានតម្លៃទាប និងសាមញ្ញ មានតួនាទីដ៏សំខាន់សម្រាប់ប្រព័ន្ធការពារក្នុងការជួយបង្ការទប់ស្កាត់អំពើហិង្សា និងការបៀតបៀនលើស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ រួមទាំងអ្នកដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងអាចប្រើជាប្រព័ន្ធផ្តល់សញ្ញាការពារសុវត្ថិភាពក្នុងការការពារស្ត្រីនិងក្មេងស្រីវ័យជំទង់ផងដែរ។

បច្ចុប្បន្នក្រសួងកិច្ចការនារី កំពុងធ្វើបរិវត្តកម្មវិធីឌីជីថលដើម្បីទប់ស្កាត់និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងគោរពតាមគោលការណ៍សិទ្ធិ និងតម្រូវការរបស់ជនរងគ្រោះ គឺជានវានុវត្តន៍មួយដែលក្រសួងកិច្ចការនារី និងអង្គការដៃគូបាននិងកំពុងអនុវត្ត ជាពិសេសក្នុងបរិបទការរីករាលដាលនៃជំងឺកូវីដ-១៩។ សកម្មភាពសំខាន់ៗ៖ ការធ្វើយុទ្ធនាការបង្ការទប់ស្កាត់តាមប្រព័ន្ធ Digital ដែលធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរាប់លាននាក់ ការបង្កើតទូរស័ព្ទជំនួយ និងការផ្តល់ប្រឹក្សាតាមប្រព័ន្ធបណ្តាញសង្គម (Facebook, WeChat, Telegram, WhatsApp, Viber។ល។ និងសេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារី សហការជាមួយក្រសួង ស្ថាប័ន និងអង្គការដៃគូ ក៏កំពុងសិក្សាការអភិវឌ្ឍន៍កម្មវិធីលើទូរស័ព្ទវៃឆ្លាតដែលមានឈ្មោះថា Mobile Application (GBV Safe App)។

គោលគំនិតក្នុងការបង្កើតកម្មវិធីនេះ គឺមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ដែលអាចជួយឱ្យជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រអាចទទួលបានតំណរភ្ជាប់ ទៅនឹងព័ត៌មាន ការផ្តល់សញ្ញា ឬព័ត៌មានពីការស្វែងរកជំនួយទៅកាន់ប្រព័ន្ធបណ្តាញទូរស័ព្ទជំនួយបន្ទាន់ ដើម្បីអន្តរាគមន៍ និងទទួលបានសេវាគាំទ្រ។


សួស្តី ខ្ញុំជាប្រព័ន្ធជំនួយរបស់ក្រសួងកិច្ចការនារី
សម្រាប់ការឆ្លើយតបសារតាមរយៈហ្វេសប៊ុក 24ម៉ោង លើ 24ម៉ោង
ដែលអាចផ្តល់ព័ត៌មានអំពីសេវាសំខាន់ចំនួន 4 រួមមាន៖
ក្រសួងកិច្ចការនារី
Business chat
1
សេវាគាំទ្រផ្លូវចិត្ត ផ្នែកច្បាប់ សង្គម សេវាបញ្ជូន និងជម្រកសុវត្ថិភាព
2
សេវាសុខភាព ក្នុងករណីមានរបួស ឬរងការរំលោភសេពសន្ថវៈ
3
ការស្វែងរកជំនួយក្នុងស្ថានភាពគ្រោះថ្នាក់ និងរាយការណ៍ពីបទល្មើសទៅមន្ត្រីនគរបាល/ប៉ូលិស ឬអាជ្ញាធរមូលដ្ឋានដែលអាចជួយអន្តរាគមន៍ទាន់ពេលវេលា
4
ផ្នែកច្បាប់ ផ្តល់ការពិគ្រោះយោបល់ពីជម្រើសក្នុងការរៀបចំពាក្យបណ្តឹង កិច្ចការពារផ្លូវច្បាប់ចំពោះជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ ជាដើម។ល។
ករណីមានចម្ងល់សូមធ្វើការទំនាក់ទំនងមកក្រសួងកិច្ចការនារី
Helpline: 093 777 900 / 085 777 900
ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS
ផលិតដោយក្រសួងកិច្ចការនារី
UNFPA
គាំទ្រថវិកាដោយរាជរដ្ឋាភិបាលជប៉ុន
តាមរយៈមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ប្រចាំប្រទេសកម្ពុជា (UNFPA)

# អបអរសាទរពិធីខួបលើកទី២៥ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ-ឈ្នះ និងខួប៥ឆ្នាំ នៃការសាងសង់វិមានឈ្នះ-ឈ្នះ

សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងកិច្ចការនារី ចូលរួមក្នុងពិធីតាំងពិព័រណ៍ ដើម្បីអបអរសាទរខួបលើកទី២៥ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ-ឈ្នះ និងខួប៥ឆ្នាំ នៃការសាងសង់វិមានឈ្នះ-ឈ្នះ ថ្ងៃទី២៩-៣១ ខែធ្នូ ឆ្នាំ២០២៣។











# « ការរីកចម្រើនរបស់ស្ត្រី អាស្រ័យដោយនយោបាយ ឈ្នះ-ឈ្នះ ! »

















# លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការទី៨ នៃរដ្ឋសភាលើវឌ្ឍនភាព និងទិសដៅការងារលើវិស័យកិច្ចការនារី នៅសាលប្រជុំប្ញាយ័ននៃរដ្ឋសភា



លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានដឹកនាំគណៈប្រតិភូ នៃក្រសួងកិច្ចការនារី ចូលជួបប្រជុំជាមួយលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា ដើម្បីរាយការណ៍អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងទិសដៅការងារ នៃវិស័យកិច្ចការនារីក្នុងនីតិកាលទី៧ នៃរដ្ឋសភា កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី៤ ខែមករា ឆ្នាំ២០២៤ ។

ក្នុងកិច្ចជំនួបនេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានបង្ហាញនូវតួនាទី និងភារកិច្ចសំខាន់ៗរបស់ក្រសួងកិច្ចការនារី ដែលជាតួអង្គសម្របសម្រួល និងជំរុញការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈយន្តការបញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ស្របតាមយុទ្ធសាស្ត្រចតុកោណកន្លងមក និងយុទ្ធសាស្ត្របញ្ចកោណនាពេលបច្ចុប្បន្ន។

វឌ្ឍនភាព និងទិសដៅអាទិភាពការងារសំខាន់ៗ ដែលបានលើកឡើងរួមមាន៖ ការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខណ្ឌគោលនយោបាយនិងកម្មវិធីជាតិ រួមទាំងការផ្សព្វផ្សាយ អប់រំ និងផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន **១.**ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី **២.**ការលើកកម្ពស់ ការអប់រំរបស់ស្ត្រីនិងក្មេងស្រី ជាពិសេសការអប់រំស្តែម (STEAM ) **៣.**ការលើកកម្ពស់សុខភាពស្ត្រី និងក្មេងស្រី **៤.**កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី **៥.**ការបង្កើនភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ និង**៦.**ការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ ។

ក្នុងឱកាសនោះ គណៈកម្មការទី៨ នៃរដ្ឋសភា និងអង្គប្រជុំបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងសមទ្ធិផលការងារកន្លងមករបស់ក្រសួង ហើយនឹងបន្តកិច្ចសហការបន្ថែមទៀតលើការងាររបស់ក្រសួង៕



# សន្និសីទភាពជាដៃគូអាស៊ាន លើកទី៤ ឆ្នាំ២០២៣

## (The 4th ACWC Partnership Conference 2023)




លោកជំទាវ **គង់ សុវិតា** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងជាជនបង្គោល នៃគណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) បានអញ្ជើញជាវាគ្មិនកិត្តិយស និងថ្លែងសុន្ទរកថាបិទក្នុងសន្និសីទភាពជាដៃគូអាស៊ានលើកទី៤ ឆ្នាំ២០២៣ (The 4th ACWC Partnership Conference 2023) នៅថ្ងៃទី១២-១៣ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារបុរីអង្គរវីស៊ត និង ស្ប៉ា ខេត្តសៀមរាប។

សន្និសីទភាពជាដៃគូអាស៊ាន លើកទី៤ ត្រូវបានរៀបចំឡើងក្រោមការសម្របសម្រួលរបស់ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងគោលបំណង៖ ១.ពង្រឹង និងពង្រីកភាពជាដៃគូ ដើម្បីឈានទៅសម្រេចបាននូវផែនការសកម្មភាពរបស់គណៈកម្មាធិការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (២០២១-២០២៥) ប្រកបដោយចីរភាព ២.សហការជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការសម្រេចឱ្យបាននូវគោលដៅរួម ក្នុងការការពារសិទ្ធិ និងលើកកម្ពស់ស្ត្រី និងកុមារ ៣.ចែករំលែក និងកៀរគរបទពិសោធន៍ ចំណេះដឹង និងធនធាន ដើម្បីជំរុញដល់ការអនុវត្តគម្រោង និងការធ្វើឱ្យប្រសើរឡើងនូវបេសសកម្មរបស់គណៈកម្មាធិការនេះ។ សន្និសីទមានការចូលរួមពីតំណាងជនបង្គោលACW ACWCពីបណ្តាប្រទេសសមាជិកអាស៊ាន អគ្គលេខាធិការដ្ឋានអាស៊ាន និងដៃគូអភិវឌ្ឍដោយផ្ទាល់ និងតាមប្រព័ន្ធ អនឡាញ។

ក្នុងនាមជាជនបង្គោល ACW ប្រចាំប្រទេសកម្ពុជា លោកជំទាវបានអញ្ជើញធ្វើជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាទី៤ លើប្រធានបទ៖ពន្លឿនដំណើរការ***ស្ត្រី សន្តិភាព និងសន្តិសុខ*** ក្នុងតំបន់អាស៊ាន (Accelerating Progress of Women, Peace and Security in ASEAN)។ លោកជំទាវបានចែករំលែកចំណុចសំខាន់ចំនួនពីរ ដូចជា៖ ចែករំលែកបទពិសោធន៍ក្នុងការរៀបចំបង្កើតឱ្យមានផែនការសកម្មភាពថ្នាក់តំបន់អាស៊ានស្តីពី "***ស្ត្រី សន្តិភាព និងសន្តិសុខ***" និង ចែករំលែកលើការរៀបចំ និងភាពជោគជ័យក្នុងការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈស្តីពី "***ស្ត្រី សន្តិភាព និងសន្តិសុខ***"។

ក្នុងពិធីបិទនៃសន្និសីទខាងលើ **លោកជំទាវ** បានថ្លែងអំណរគុណដល់អ្នកចូលរួម ក្នុងកិច្ចពិភាក្សាយ៉ាងសកម្ម ដែលធ្វើឱ្យសន្និសីទទាំងពីរថ្ងៃនេះប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានលទ្ធផល ផ្លែផ្កាដូចជាការរំពឹងទុក ដើម្បីឆ្ពោះទៅរកគោលដៅរួម ក្នុងការការពារសិទ្ធិ និងលើកកម្ពស់ស្ត្រី និងកុមារសម្រាប់ថ្នាក់ជាតិ និងថ្នាក់តំបន់៕



# លោកជំទាវ ត្រ ណាល់លីស៖ បទពិសោធន៍មួយរបស់ស្ត្រី ដែលសិក្សា និងធ្វើការនៅក្នុងវិស័យវិទ្យាសាស្ត្រ និងវិស្វកម្ម






លោកជំទាវ **ត្រ ណាល់លីស** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី លោកជំទាវបានបញ្ចប់ការសិក្សាជំនាញវិស្វកម្ម គ្រឹះភូគព្ភសាស្ត្រ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ) បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ជំនាញវិទ្យាសាស្ត្ររូបធាតុ នៅប្រទេសម៉ាឡេស៊ី និងប្រទេសជប៉ុន។

តើមូលហេតុអ្វីខ្លះដែលជំរុញលោកជំទាវឱ្យជ្រើសរើសជំនាញនេះ? តើបទពិសោធន៍អ្វីខ្លះក្នុងការជំនះផ្នត់គំនិតយេនឌ័រ ក្នុងការចាប់យកជំនាញ ?

លោកជំទាវបានចែករំលែកថា៖ **ទី១.** ការជ្រើសរើសបុគ្គលគំរូ (Role Model) ដែលយើងស្រឡាញ់ចូលចិត្ត គឺសំខាន់វានឹងជំរុញទឹកចិត្តរបស់យើងឱ្យខិតខំប្រឹងប្រែង ដើម្បីអាចមានភាពជោគជ័យ ដូចបុគ្គលនោះដែរ។ **ទី២.** គឺជាចំណែកដ៏សំខាន់ដែលមិនអាចខ្វះបាន គឺការតម្រង់ទិស និងគាំទ្រពីឪពុកម្តាយ បងប្អូន និងលោកគ្រូ អ្នកគ្រូ។

លោកជំទាវមានប្រសាសន៍ថា «ខ្ញុំមានសំណាង ដែលលោកឪពុករបស់ខ្ញុំ គាត់មិនបានប្រាប់ខ្ញុំថា ជំនាញវិស្វកម្មមិនមែនជាជំនាញរបស់កូនស្រី ប៉ុន្តែគាត់តែងតែតម្រង់ទិស និងប្រាប់ឱ្យខ្ញុំខំរៀននូវមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ព្រមទាំងភាសាបារាំង ដើម្បីប្រឡងចូលរៀននៅសាលាតិចណូ»។

នៅក្នុងនោះ លោកជំទាវបន្តថា នៅពេលបន្តការសិក្សាថ្នាក់បណ្ឌិត គាត់ក៏ជួបប្រទះនូវការលើកឡើងបែបអវិជ្ជមានជាច្រើន ប៉ុន្តែគាត់មិនបានផ្លាស់ប្តូរការសម្រេចចិត្តឡើយ ដោយសារលោកជំទាវទទួលបានការគាំទ្រពេញទំហឹងពីឪពុកម្តាយ និងបងប្អូន។

មុនពេលលោកជំទាវចូលបម្រើការងារនៅក្រសួងកិច្ចការនារី លោកជំទាវធ្លាប់បម្រើការងារនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ការចូលរួមរបស់លោកជំទាវ ក្នុងការងារកិច្ចការនារី លោកជំទាវមានការតាំងចិត្តខ្ពស់ ក្នុងការប្រើប្រាស់នូវបទពិសោធន៍ នៃការសិក្សារៀនសូត្រ និងការបំពេញការងារនាពេលកន្លងមក ក្នុងការបង្កើនការចូលរួមចំណែករបស់ស្ត្រី និងក្មេងស្រីដោយស្មើភាពគ្នាជាមួយបុរស និងក្មេងប្រុសលើគ្រប់វិស័យក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

លោកជំទាវជូនយោបល់ដល់ស្ត្រី និងក្មេងស្រីថា កុំយកភេទមកដាក់ជាគំនាបសម្រាប់ខ្លួន ត្រូវគិតថា ស្ត្រី និងបុរសមានសិទ្ធិ និងឱកាសដូចគ្នា ក្នុងការចាប់យកជំនាញសិក្សា និងបំពេញការងារដែលខ្លួនស្រឡាញ់ពេញចិត្ត។ សូមស្ត្រី និងក្មេងស្រីទាំងអស់ រៀនបង្កើតឱកាស និងផ្តល់ឱកាសសម្រាប់ខ្លួនឯង តាមរយៈការទុកចិត្តលើសមត្ថភាពរបស់ខ្លួន ការបង្ហាញសមត្ថភាព និងអភិវឌ្ឍសមត្ថភាពជាដរាប៕



# នារីខ្មែរដំបូងជាវិស្វករសម្លេង






កញ្ញា **គាំម ស្រីម៉ុច** ជានារីវិស្វករផ្នែករចនាសម្លេងសម្រាប់ខ្សែភាពយន្តអន្តរជាតិដំបូងគេ ក្នុងប្រទេសកម្ពុជា។ វិស្វករសម្លេង ឬអ្នករចនាសម្លេង ដើរតួយ៉ាងសំខាន់ក្នុងការកាត់តសម្លេងឱ្យបន្ស៊ីសម្លេងពីរ ឬច្រើនក្នុងពេលតែមួយ ដើម្បីបង្ហាញពីតថភាពពិតឱ្យដូចធម្មជាតិ។ សម្លេងគឺជាបេះដូងនៃភាពយន្ត ឬវីដេអូ។ កញ្ញាបានបញ្ចប់ការសិក្សាទុតិយភូមិនៅឆ្នាំ២០១៨ បន្ទាប់មកទៅបន្តការសិក្សានៅសាលាភាពយន្តអង្គការភាពញញឹម នៃកុមារ រយៈពេលជាង១ឆ្នាំ។ ក្នុងអំឡុងពេលសិក្សាក្រុមហ៊ុនកងចក្រ (KongChak )បានមកធ្វើសិក្ខាសាលា ដើម្បីផ្លាស់ប្តូរបទពិសោធន៍។ ប្រធានផ្នែកខាងសម្លេងក្នុងក្រុមហ៊ុន KongChak ដែលជាជនជាតិបារាំងបានចាប់អារម្មណ៍ **ស្រីម៉ុច** ក៏បានជ្រើសរើសឱ្យមកធ្វើការជាមួយតាំងពីឆ្នាំ២០១៨ ដល់បច្ចុប្បន្ន ដោយសិក្សាបណ្តើរអនុវត្តការងារបណ្តើរ។ កញ្ញាធ្វើការជាអ្នករចនាសម្លេងក្នុងក្រុមហ៊ុនKongChak នេះបានរយៈពេល ៦ឆ្នាំហើយ ដោយការតាំងចិត្តខ្ពស់រួមជាមួយការស្រឡាញ់ កញ្ញាមិនបានបញ្ចប់ក្តីស្រមៃត្រឹមនេះទេ ដោយចង់ក្លាយជាអ្នករចនាសម្លេងជាលក្ខណៈអន្តរជាតិ ដែលល្បីដើម្បីឱ្យពិភពលោកទទួលស្គាល់។ ដោយមានការជួយជ្រោមជ្រែងពីក្រុមគ្រួសារទាំងស្មារតី និងការផ្តល់កម្លាំងចិត្តរួមទាំងបទពិសោធន៍ពីប្រធានផ្នែកខាងសម្លេងក្នុងក្រុមហ៊ុន មិត្តភក្តិ ពិសេសពីរៀមច្បងបច្ចុប្បន្ននេះកញ្ញាបានក្លាយជាវិស្វករផ្នែកសម្លេងសម្រាប់ខ្សែភាពយន្តអន្តរជាតិដែលបាននាំយកទៅដាក់បញ្ចាំងនៅក្រៅប្រទេសដោយបានរំលេចឈ្មោះកញ្ញានៅលើ Plat Form «**ផលិតករភាពយន្តនារីវ័យក្មេងមកពីប្រទេសកម្ពុជា**» ដែលជាមោទនភាពរបស់ប្រទេសកម្ពុជាយើងនៅលើឆាកអន្តរជាតិ លើជំនាញនៃការរចនាផ្នែកសម្លេងភាពយន្តអន្តរជាតិ។

ស្ថិតក្នុងទឹកមុខស្រស់ស្រាយបង្កប់ដោយភាពម៉ឺងម៉ាត់ កញ្ញាបានប្រាប់អ្នកយកព័ត៌មាននារីរតនៈយើងថា៖ «*ខ្ញុំមានមោទនភាពក្រៃលែង ដែលក្តីស្រមៃរបស់ខ្ញុំក្លាយជាការពិត មានតែខ្ញុំម្នាក់គត់ជានារីវិស្វករផ្នែកសម្លេងសម្រាប់ខ្សែភាពយន្តអន្តរជាតិដំបូងគេ។ នេះដោយសារខ្ញុំមានការលះបង់ និងមានឆន្ទៈប្រឹងប្រែងរៀនសូត្រដើម្បីពង្រឹងសមត្ថភាព*»។

កញ្ញាសង្កត់ធ្ងន់ថា ការងារនេះត្រូវមានទំនួលខុសត្រូវ និងការសម្រេចចិត្តខ្ពស់ជាងការងារផ្សេងៗ ព្រោះក្នុងការអនុវត្តការងារមានឧបករណ៍ស្មុគស្មាញច្រើនដែលយើងត្រូវប្រើប្រាស់វាឱ្យបានត្រឹមត្រូវ ដូច្នេះទាមទារការស្រាវជ្រាវនូវអ្វីដែលថ្មីៗ ហើយប្លែក និងស្វ័យសិក្សារួមជាមួយនូវចំណេះដឹងភាសាអង់គ្លេសស្ទាត់ជំនាញ ដើម្បីទំនាក់ទំនងជាមួយដៃគូការងារ ក៏ដូចជាការប្រើឧបករណ៍ផ្សេងៗ និងត្រូវចេះគណិតវិទ្យា រួមទាំងសុខភាពល្អ កាយសម្បទាមាំមួន ព្រោះជាការងារត្រូវការបច្ចេកទេសខ្ពស់។

ដើម្បីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ក្រោមមូលបទ «**ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល**» កញ្ញាបានបញ្ចេញទស្សនៈផ្ទាល់ខ្លួនថា «*បើបំណងយើងចង់ធ្វើការអ្វីមួយ យើងត្រូវចាប់យកឱកាសឱ្យបាន ព្រោះសម័យនេះជាសម័យឌីជីថល យើងត្រូវបង្ហាញពីសមត្ថភាពទេពកោសល្យ និងភាពប៉ិនប្រសព្វរបស់ខ្លួនឯង ទៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដូច Plat Form ផ្សេងៗ ទោះតិចឬច្រើនឆាប់ ឬយូរ គេនឹងជឿជាក់លើសមត្ថភាព យើងមិនខាន! កុំបោះបង់ក្តីស្រឡាញ់របស់យើងឱ្យសោះ!* »។

ចុងក្រោយកញ្ញា **ស្រីម៉ុច** បានផ្តាំផ្ញើដល់បងប្អូននារីដែលមានចំណូលចិត្តលើការងារនេះសូមកុំរុញរា ត្រូវប្រឹងប្រែងហាត់រៀន ការងារអ្វីក៏ស្ត្រីអាចធ្វើបានដូចបុរសដែរ សំខាន់ត្រូវមានការតាំងចិត្តខ្ពស់ មានឆន្ទៈ ដូចជារូបខ្ញុំជាគំរូស្រាប់សម្រាប់យុវតីដទៃទៀតក្នុងការសម្រេចក្តីស្រមៃរបស់ខ្លួន។ ហេតុនេះត្រូវមានជំនឿលើខ្លួនឯងព្រោះជាមោទនភាពសម្រាប់គ្រួសារក៏ដូចប្រទេសជាតិទាំងមូលដែរ៕ ***ខេមរា***

# អ្នកបង្កើតមាតិកាលើបណ្ដាញសង្គម



កញ្ញា **ស្រីនា** ជាInfluencer និងជាសហគ្រិនវ័យក្មេង We young ដើម្បីចូលរួមអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបទី១១៣ ក្រោមមូលបទ «**ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល**» តាមទស្សនៈរបស់ **ស្រីនា** យល់ឃើញថា៖« ការលើកឡើងនេះពិតជាល្អមែនទែន ដោយសារតែសម័យនេះ អ្វីៗគ្រប់យ៉ាងទាក់ទងនឹងឌីជីថល ឬធ្វើការរកស៊ីតាម online ផ្សេងៗ យើងអាចប្រើតាមបច្ចេកវិទ្យា ជាពិសេសបណ្ដាញសង្គម ត្រូវធ្វើរឿងជាច្រើនតាមរយៈការបង្ហាញពីអ្វីដែលខ្លួនឯងមាន។ ដូចនេះ ក្នុងនាមយើងជាស្ត្រី ឬជាស្ត្រីវ័យក្មេងស្រស់ស្អាត តែងមានក្ដីស្រមៃច្រើន ហើយក៏ចង់ធ្វើរឿងជាច្រើនផងដែរ។ នៅក្នុងសម័យបរិវត្តកម្មឌីជីថលនេះ យើងទាំងអស់គ្នាអាចចាប់យកឱកាសនេះ ដើម្បីប្រកបអាជីវកម្ម ឬចែករំលែកនូវអ្វីដែលយើងមាន។ ជាក់ស្ដែងរូបខ្ញុំផ្ទាល់កាលនៅសម័យកូវីត មិនអាចចេញក្រៅបានទេ ប៉ុន្តែដោយសារតែមានបច្ចេកវិទ្យានេះហើយ ដែលអាចឱ្យខ្ញុំនៅតែអាចចែករំលែកនូវអ្វីល្អៗ ជាពិសេស ការធ្វើអាជីវកម្មរបស់ខ្ញុំ ក៏ដូចជាមាតិកា (content) របស់ខ្ញុំ មានការរីកចម្រើនមែនទែននៅក្នុងសម័យកូវីត។ សម្រាប់ខ្ញុំដំបូងបង្អស់ គឺខ្ញុំបានចាប់ផ្ដើមធ្វើវីដេអូ make up ពីជំហានតូចមួយហ្នឹងហើយ ដែលធ្វើឱ្យខ្ញុំក្លាយទៅជាខ្ញុំមកដល់សព្វថ្ងៃនេះ ។

ដូចនេះសំរាប់បងប្អូនទាំងអស់គ្នាដែលចង់ប្រកបរបរអ្វីផ្សេងៗ មិនថាអាជីវកម្ម ឬមួយប្រធានបទអ្វីល្អៗ សូមកុំគិតថាខ្ញុំអៀន ខ្ញុំអត់ទាន់ចេះអី ។ល។ យើងត្រូវគិតថាសម័យនេះ ជាសម័យ Tik Tok ឱ្យតែយើងខិតខំធ្វើបានលទ្ធផលហើយ post រាល់ថ្ងៃ ជាក្ដីស្រឡាញ់ធ្វើចេញពីបេះដូង ខ្ញុំជឿជាក់ថា ថ្ងៃណាមួយយើងនឹងអាចទទួលជោគជ័យជាមិនខាន។

ជាចុងក្រោយ ខ្ញុំសូមផ្ដាំផ្ញើទៅកាន់ស្ត្រី និងក្មេងស្រីកម្ពុជាទាំងឡាយ ជាពិសេសនៅក្នុងដំណើរការបរិវត្តកម្មឌីជីថល (Digital Transformation) នេះ សូមប្រើប្រាស់ជាមួយបច្ចេកវិទ្យា ជាពិសេសបណ្ដាញសង្គម ( Social Media ) នៅក្នុងការបង្ហាញទេពកោសល្យ មិនថាគំនិតចែករំលែកអ្វីផ្សេងៗទេ គឺយើងអាចប្រើប្រាស់វាបានក្នុងការផ្លាស់ប្ដូរផ្នត់គំនិត ហើយយើងត្រូវធ្វើការរួមគ្នា ដើម្បីអាចឈរលើគោលជំហរស្មើៗគ្នាបាន៕

---



រីឯ DJ **ណារាណា** ចង់ចែករំលែកទៅកាន់នារីៗយើងថា៖ «ខ្ញុំជាអ្នកម្ដាយដែលមានកូនប្រុសពីររូប ហើយការងារចម្បងគឺជាអ្នកបង្កើតមាតិកានៅតាមបណ្ដាញសង្គម និយាយភាសាសាមញ្ញថា រកស៊ីនៅលើ Facebook»។

សម័យនេះ ជាសម័យឌីជីថល ចង់មិនចង់ក៏គ្មានជម្រើសដែរ គឺយើងនៅក្នុងសម័យឌីជីថលហ្នឹងហើយ។ មានទាំងគុណសម្បត្តិ និងគុណវិបត្តិ ប៉ុន្តែការពិតមួយ គឺយើងមិនអាចទាញក្មេងស្រី ឬក្មេងប្រុសណាម្នាក់ចេញពីឌីជីថលបានទេ ពីព្រោះក្មេងៗចាប់ផ្ដើមមាន Facebook account, Tik Tok, Instagram ហើយពួកគាត់ទំនាក់ទំនងគ្នានៅតាមហ្នឹង។ អញ្ចឹងឪពុកម្ដាយចង់ទៅឃាត់ គឺតាមអត់ទាន់

ក្មេងទេ។ ដូច្នេះត្រូវដើរឱ្យទាន់បច្ចេកវិទ្យា ឪពុកម្តាយ ស្រ្តី បុរស គឺត្រូវតែមានការអប់រំផ្នែកបច្ចេកវិទ្យាមិនថាជាកំរិតរៀនសូត្រតាមសាលា ឬតាមរយៈការរស់នៅប្រចាំថ្ងៃនោះទេ។ សម័យ Facebook នេះ មនុស្សស្រី ក្មេងស្រីៗនៅតែក្នុងចង្ក្រានធ្វើម្ហូប ក៏រកលុយបានដែរ ព្រោះពួកគាត់បង្កើតមាតិកាទាក់ទងជាមួយនឹងរបៀបធ្វើម្ហូបមើលតាមរយៈ influencer ឬក៏ KOL ផ្សេងៗទៀត ធ្វើមាតិកាទាក់ទងហ្នឹងពួកគាត់បានរៀន ដូច្នេះកត្តារាំងស្ទះសម្រាប់ពួកគាត់គឺមានកាន់ តែតិចទៅៗ។

សូមឱ្យប្អូនៗ ក្មួយស្រីៗទាំងអស់ចាំថានៅក្នុងសម័យឌីជីថលនេះ ឱកាសមានច្រើន ស៊ីសងលើយើងចេះចាប់យក ឬមិនចាប់យក សូមចាប់ផ្តើមត្រឡប់ទៅមើល friends របស់យើងនៅក្នុងបណ្តាញសង្គម តើ friends ដែលយើងមានជា friend មនុស្សស្គាល់គ្នា ជាមិត្តភក្តិ ឬក៏ជាមនុស្សមិនដែលស្គាល់គ្នា។ តើនៅលើ new feed របស់យើង ធម្មតាទេ យើងlike មនុស្សបែបណា join group ប្រភេទណានៅលើ new feed របស់យើង វានឹងចេញព័ត៌មានដែលទាក់ទងជាមួយពួកគាត់។ ខ្ញុំចង់ឱ្យប្អូនៗសាកឆ្លុះបញ្ចាំងថា តើនៅលើ new feed របស់យើងហ្នឹងប៉ុន្មានភាគរយជារឿងមានប្រយោជន៍ ឬមនុស្សមានប្រយោជន៍ ? ប៉ុន្មានភាគរយដែលជារឿងអត់ប្រយោជន៍ ? តើវាជះឥទ្ធិពលយ៉ាងមិច ? ការពិតត្រូវរៀនសូត្រពីបណ្តាញសង្គម ថាតើបច្ចេកវិទ្យាដើរដល់ណា? ដើម្បីឱ្យយើងទទួលប្រយោជន៍បានច្រើនបំផុតពីបណ្តាញសង្គម និងចៀសវាងក្លាយជាជនរងគ្រោះដោយសារបណ្តាញសង្គម។

---

ដោយឡែក **កញ្ញា ឆម ស្រីផាច** ជាអ្នកផលិតវីដេអូធ្វើម្ហូបខ្មែរបែបស្រុកស្រែ បច្ចុប្បន្នរស់នៅខេត្តបន្ទាយ-មានជ័យ។



ដើម្បីចូលរួមអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបទី ១១៣ ក្រោមមូលបទ **«ស្រ្តី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល»** តាមទស្សនៈរបស់ខ្ញុំយល់ឃើញថា៖ «តាមពិតប្រព័ន្ធឌីជីថល មិនថាក្មេងស្រី ឬវ័យប៉ិនខ្ញុំ យើងអាចធ្វើបាន ដោយសារប្រព័ន្ធឌីជីថលរាល់ថ្ងៃជឿនលឿនខ្លាំងមែនទែន យើងអាចធ្វើការស្រាវជ្រាវពីការសិក្សា ស្រាវជ្រាវពីទេសចរណ៍ ឬក៏អាចផលិតមាតិកាពីម្ហូប ដូចជារូបខ្ញុំ ធ្វើមាតិកាទាក់ទង នឹងការធ្វើម្ហូប ទេសចរណ៍ ដំណើរកំសាន្ត ឬមួយទាក់ទងនឹងសង្គម ឱ្យតែយើងធ្វើទាក់ទងនឹងរឿងល្អៗ យើងទទួលជោគជ័យ» ។

**ស្រីផាច**សូមលើកឡើងពីបទពិសោធន៍ផ្ទាល់ខ្លួនថា៖ កម្មវិធីឌីជីថល និយាយមួយម៉ាត់ទៅគឺយើងធ្វើ ឬផលិតនូវមាតិកានីមួយៗ ធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់អ្នកដទៃ និងបង្កបញ្ហាដល់សង្គមជាតិ។ ហើយកម្មវិធីឌីជីថល (digital) នេះ យើងអាចស្រូបយកចំណេះពីវា រកចំណូលបានច្រើនខ្លាំងមែនទែន ជួយបង្កើនជីវភាពគ្រួសារថែមទៀត ទន្ទឹមនឹងយើងធ្វើបានជោគជ័យ ក៏ត្រូវការភាពអំណត់តស៊ូខ្លាំងផងដែរ។

សម្រាប់ស្រ្តី ឬក្មេងស្រី នាពេលបច្ចុប្បន្ននេះគួរធ្វើអ្វីដែលជាខ្លួនយើង ត្រូវជឿជាក់លើខ្លួនឯង មិនថាក្មេង ឬចាស់ទេ សំខាន់ក្នុងចិត្តគិតថាអាចធ្វើបាន ប៉ុន្តែគួរតែចាប់យកចំណុច ឬផ្នែកណាមួយដែលយើងមានស្រាប់។ ឧទាហរណ៍ ដូចរូបខ្ញុំផ្ទាល់ « ខ្ញុំជាអ្នកបង្កើតមាតិកា (content) ទាក់ទងនឹងការធ្វើម្ហូបខ្មែរបែបស្រុកស្រែ គឺឪពុករបស់ខ្ញុំគាត់ជាអ្នកដាំបន្លែ អញ្ចឹងខ្ញុំចាប់ផ្តើមធ្វើទៅ គឺទទួលជោគជ័យហើយ ដោយសារនៅជុំវិញខ្លួនខ្ញុំមានអ្វីៗទាំងអស់ មិនចាំបាច់គិតថាទាល់តែមានកន្លែងស្អាត មានរបស់ល្អៗស្រស់បំព្រងនោះទេ គឺយើងធ្វើតែអ្វីដែលយើងមាន យើងអាចធ្វើបាន៕

# ពានរង្វាន់ឌីជីថលកម្ពុជា និងពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា ឆ្នាំ២០២៣




ពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា ធ្វើឡើងក្នុងគោលបំណង ដើម្បីលើកកម្ពស់ការចូលរួមស្ត្រីប្រកបដោយបរិយាបន្ន និងការទទួលស្គាល់នូវសមិទ្ធផលរបស់ស្ត្រីជាវិស្វករបច្ចេកវិទ្យា អ្នកច្នៃប្រឌិត មន្ត្រីរាជការ យុវនារី និងសហគ្រិនក្នុងវិស័យឌីជីថល ព្រមទាំងជាវេទិកាសម្រាប់ស្ត្រីក្នុងការចែករំលែក ចំណេះដឹង បទពិសោធន៍ និងបង្កើតទំនាក់ទំនងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា។

ពានរង្វាន់ឌីជីថលកម្ពុជា និងពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា ឆ្នាំ២០២៣ មានក្រុមហ៊ុនជ័យលាភីចំនួន៥ ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យជាង៥០ ក្រុមហ៊ុនស្ថាប័នដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យ ៤ ចំណុច គឺការច្នៃប្រឌិតបច្ចេកវិទ្យា ការដោះស្រាយបញ្ហា ប្រសិទ្ធភាពនៃប្រតិបត្តិការ និងយុទ្ធសាស្ត្រទីផ្សារ។

យោងតាមប្រសាសន៍របស់ **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងពិធីប្រគល់ពានរង្វាន់ឌីជីថលកម្ពុជា និងពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា ឆ្នាំ២០២៣ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ ពានរង្វាន់ស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យាបេក្ខនារីចំនួន ៥រូប ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដាក់ពាក្យជាង ៦០រូប។ ជ័យលាភីទាំង ៥រូប ដែលទទួលបានពានរង្វាន់ រួមមាន៖

**(១).** ពានរង្វាន់យុវតីឌីជីថលឆ្នើមប្រចាំឆ្នាំ (Digital Youngster of the Year) ត្រូវបានផ្តល់ជូន កញ្ញា **ជុន ផល្លាមនុញ្ញ** ជានិស្សិតសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ។

**(២).**ពានរង្វាន់ស្ត្រីអ្នកច្នៃប្រឌិតឌីជីថលឆ្នើមប្រចាំឆ្នាំ (Digital Creative of the Year) ត្រូវបានផ្តល់ជូន កញ្ញា **ម៉េង ម៉ូលីនណា** អ្នកបង្កើតមាតិកាឯករាជ្យ។

**(៣).**ពានរង្វាន់ស្ត្រីវិស្វករឌីជីថលឆ្នើមប្រចាំឆ្នាំ (Digital Engineer of the Year) ត្រូវបានផ្តល់ជូន កញ្ញា **ទេស ពុទ្ធីរ៉ា** មកពីក្រុមហ៊ុន ADITI ។

**(៤).** ពានរង្វាន់ស្ត្រីសហគ្រិនឌីជីថលឆ្នើមប្រចាំឆ្នាំ(Digital Entrepreneur of the Year) ត្រូវបានផ្តល់ជូន លោកស្រី **ចៅលន់ មូលីភារ** ប្រធានក្រុមហ៊ុន Sophea Moly Agro-Retails & Trading Co., Ltd.។

**(៥).**ពានរង្វាន់ស្ត្រីឆ្នើមក្នុងនវានុវត្តន៍រដ្ឋាភិបាលឌីជីថលប្រចាំឆ្នាំ (Female Digital Government Innovator) ត្រូវបានផ្តល់ជូន កញ្ញា **អ៊ុង សុម៉ី** មកពីធនាគារជាតិ នៃកម្ពុជា។

កម្មវិធីពានរង្វាន់ទាំងពីរទទួលការឧបត្ថម្ភនិងគាំទ្រពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី ទីភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់ (GIZ) ប្រចាំកម្ពុជា មូលនិធិ ស.អ. ក្រុមហ៊ុន Smart Axiata និង Huawei Technologies (Cambodia)៕

# យុវតី អ៊ុង ហៀកលីញ ពានរង្វាន់ផលិតរ៉ូបូត




យុវតី **អ៊ុង ហៀកលីញ** មានអាយុ ១៩ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ជាកូនពៅនៅក្នុងគ្រួសារដែលមានឪពុកម្តាយជាអ្នកធ្វើចម្ការ ហើយបច្ចុប្បន្នកំពុងសិក្សានៅបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាក្នុងរាជធានីភ្នំពេញ។**ហៀកលីញ** ជាសិស្សម្នាក់ដែលឧហ្សាហ៍ព្យាយាមក្នុងការរៀនសូត្រ និងតែងទទួលបានចំណាត់ថ្នាក់ល្អនៅក្នុងថ្នាក់តាំងពីបឋមសិក្សា រហូតមកដល់វិទ្យាល័យ។ កាលពីថ្នាក់ទី៩ យុវតីរូបនេះធ្លាប់ទទួលបានចំណាត់ថ្នាក់លេខ៣ ក្នុងការប្រឡងសិស្សពូកែគណិតវិទ្យា ទូទាំងខេត្តបន្ទាយ-មានជ័យ ហើយទទួលបាននិទ្ទេស A សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំសិក្សា២០២០-២០២១។

***...«មូលហេតុចម្បងដែលជម្រុញឱ្យនាងខ្ញុំរៀនផ្នែកផលិតរ៉ូបូតនេះ គឺផ្តើមចេញពីក្តីស្រឡាញ់ ចូលចិត្តចង់ដឹងពីបច្ចេកវិទ្យារ៉ូបូត ពីព្រោះវាជាជំនាញដែលថ្មី ប្លែកកើតចេញពីភាពច្នៃប្រឌិតរបស់អ្នកផលិត ។ មួយវិញទៀតដោយសារតែការមើលឃើញពីភាពជឿនលឿនផ្នែកបច្ចេកវិទ្យារ៉ូបូតរបស់ប្រទេសដទៃ ដែលធ្វើឱ្យនាងខ្ញុំចង់ជួយដល់ប្រទេសខ្លួនឱ្យមានការរីកចម្រើនផ្នែកនេះផងដែរ»។***

**ហៀកលីញ** បានបន្ថែមថា អំឡុងពេលសិក្សាខ្លួនមានបញ្ហាប្រឈមមួយចំនួន តែយុវតីរូបនេះនៅតែខិតខំសិក្សា និងធ្លាប់បានចូលរួមការប្រកួតកម្មវិធីបច្ចេកវិទ្យាចំនួន៣ដង ដូចជា កម្មវិធីប្រកួតរ៉ូបូតថ្នាក់ជាតិ Robocon2023 កម្មវិធី Innovation Festival 2023 (ចំណាត់ថ្នាក់លេខ៣) និងការផលិតឧបករណ៍វាស់កម្ពស់ទឹក ដើម្បីចូលរួមក្នុងកម្មវិធី River Monitoring Technology ដែលរៀបចំឡើងដោយ Mekong River Commission នៅប្រទេសឡាវ ដែលទទួលបានចំណាត់ថ្នាក់លេខ១ ផ្នែក Water Level ។**ហៀកលីញ** បានលើកឡើងថា ***«ក្នុងនាមជាយុវសិស្សម្នាក់ដែលរៀនជំនាញបច្ចេកវិទ្យា និងមានបទពិសោធន៍ផលិតរ៉ូបូត នាងខ្ញុំសុំលើកទឹកចិត្តឱ្យសិស្សានុសិស្សដទៃទៀត ងាកមកចាប់អារម្មណ៍លើជំនាញមួយនេះ ហើយចាប់យកឱកាសចូលក្នុងវិស័យរ៉ូបូតដែលកំពុងតែមានការវិវត្តន៍ខ្លាំង ព្រោះការធ្វើរ៉ូបូតតម្រូវឱ្យអ្នកមានជំនាញផ្សេងៗមកជួយគ្នាក្នុងការផលិត ដែលធ្វើឱ្យយើងអាចរៀនបានពីមិត្តរួមក្រុម និងធ្វើការក្នុងបរិបទថ្មីមួយទៀតដែលគួរឱ្យចាប់អារម្មណ៍។ ជាពិសេសគឺ អមជាមួយនឹងការអនុវត្តតាមរយៈការចូលរួមក្នុងការប្រកួតប្រជែងនានា ដើម្បីឱ្យយើងអាចទទួលបានបទពិសោធន៍ថ្មីប្លែកខុសពីការសិក្សាទ្រឹស្តី។»*** នៅថ្ងៃអនាគត យុវតីរូបនេះចង់ក្លាយជាវិស្វកររ៉ូបូតម្នាក់ ដែលបង្កើតជាសមិទ្ធផលថ្មីៗ ដើម្បីឱ្យមានទំនើបកម្មក្នុងការរស់នៅ និងរំពឹងបន្តយកអាហារូបករណ៍ថ្នាក់អនុបណ្ឌិត នៅក្រៅប្រទេស ដើម្បីក្រេបយកចំណេះវិជ្ជា និងរៀនសូត្រពីពិភពខាងក្រៅមកអភិវឌ្ឍប្រទេសឱ្យរីកចម្រើនជឿនលឿន ខាងផ្នែកបច្ចេកវិទ្យា។ ជាចុងក្រោយ **ហៀកលីញ** បានផ្តាំផ្ញើដល់សិស្សានុសិស្សដែលចង់ចាប់យកជំនាញផលិតRobotsនេះមិនថាជានារី ឬបុរស សុទ្ធតែអាចរៀនជំនាញនេះបានដូចគ្នា ហើយឥឡូវនេះកំពុងតែមានតម្រូវការខ្លាំងទាំងក្នុងឧហ្សាហកម្ម ក៏ដូចជាស្ថាប័នផ្សេងៗ គឺទាមទារឱ្យមានធនធានមនុស្សចូលរួមអភិវឌ្ឍប្រទេសជាតិយើង។ *សោភា*

# យុវតី ឡេង សុគន្ធផុស្សតី សិស្សទទួលបាននិទ្ទេស A គ្រប់មុខវិជ្ជា





យុវតី **ឡេង សុគន្ធផុស្សតី** អាយុ ១៧ឆ្នាំ ជាសិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ មុខវិជ្ជាវិទ្យាសាស្ត្រពិត នៅក្នុងលទ្ធផលប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ៦ វិច្ឆិកា ២០២៣។ បេក្ខជនដែលប្រឡងជាប់សរុបមានចំនួន ៩៨ ៤៦០នាក់ ស្មើនឹង ៧២.៨៩%។ **សុគន្ធផុស្សតី** ជាសិស្សទទួលបាននិទ្ទេសAគ្រប់មុខវិជ្ជា លើពិន្ទុ៩៩.៩៩៩។

យុវតី **សុគន្ធផុស្សតី** ជាសិស្សទទួលបាននិទ្ទេស A មានប្រវត្តិរៀនពូកែទទួលបានចំណាត់ថ្នាក់លេខ ១ តាំងពីបឋមសិក្សាថ្នាក់ទី ២ រហូតដល់ថ្នាក់ទី ១២។ **សុគន្ធផុស្សតី** បាន ដាក់គោលដៅសិក្សាបន្តដល់ថ្នាក់បណ្ឌិត និងចង់ទៅសិក្សានៅបរទេស។ ទៅថ្ងៃអនាគតនាងចង់ក្លាយទៅជាអ្នកវិទ្យាសាស្ត្រម្នាក់ ។

**សុគន្ធផុស្សតី** បានប្រាប់ថានាងធ្លាប់បានចូលរួមប្រកួតប្រជែងជាច្រើន ពិសេសការប្រកួតមុខវិជ្ជាគណិតវិទ្យា ។ បច្ចុប្បន្ន **សុគន្ធផុស្សតី** មានពានរង្វាន់ជ័យលាភីលេខ១ចំនួន១ មេដាយមាស ប្រាក់ និងមេដាយសំរឹទ្ធ ចំនួន១៨គ្រឿង រួមទាំងលិខិតសរសើរជាច្រើនទៀត។

ក្នុងនាមជាសិស្សជោគជ័យមួយរូប ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ ២០២៣នេះ **សុគន្ធផុស្សតី** សូមផ្តាំទៅសិស្សដទៃទាំងអស់ថា ដើម្បីរៀនពូកែបានពិន្ទុខ្ពស់គ្រប់មុខ ត្រូវតែដាក់គោលដៅឱ្យច្បាស់លាស់ និងត្រូវប្រឹងពីថ្នាក់អនុវិទ្យាល័យទៅ ព្រោះគ្រប់វិជ្ជា នៃមេរៀនមានការពាក់ព័ន្ធគ្នា ពីថ្នាក់មួយទៅថ្នាក់មួយ។ ត្រូវស្វែងយល់ពីចំណុចខ្វះខាតរបស់ខ្លួន ហើយត្រូវបំពេញបន្ថែមស្វ័យសិក្សាខ្លួនឯង និងមានការចូលរួមប្រឹក្សាលើកទឹកចិត្តពីឪពុកម្តាយក្រុមគ្រួសារផងដែរ។

ជាចុងក្រោយនាងខ្ញុំសូមអរគុណម៉ាក់ប៉ាតែងលើកទឹកចិត្តនាងខ្ញុំជានិច្ច និងលោកគ្រូអ្នកគ្រូតែងបានបង្ហាត់បង្រៀននាងខ្ញុំ មានថ្ងៃនេះក៏ដោយសារអ្នកទាំងអស់គ្នា៕

# តារាងស្ថិតិសិស្សប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡងឆ្នាំ២០២៣

| ល.រ | រាជធានី-ខេត្ត | A | | B | | C | | D | | E | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | កណ្តាល | 148 | 91 | 611 | 355 | 1650 | 1002 | 2837 | 1746 | 2921 | 1579 |
| 2 | តាកែវ | 85 | 51 | 491 | 285 | 1347 | 861 | 2582 | 1491 | 2764 | 1391 |
| 3 | កែប | 0 | 0 | 14 | 11 | 49 | 35 | 109 | 59 | 81 | 40 |
| 4 | កំពត | 91 | 48 | 331 | 213 | 901 | 568 | 1526 | 881 | 1569 | 782 |
| 5 | ព្រះសីហនុ | 40 | 24 | 122 | 70 | 287 | 167 | 547 | 296 | 527 | 272 |
| 6 | កោះកុង | 3 | 2 | 51 | 24 | 145 | 76 | 272 | 148 | 380 | 197 |
| 7 | កំពង់ឆ្នាំង | 22 | 12 | 194 | 129 | 495 | 320 | 972 | 620 | 1132 | 634 |
| 8 | ពោធិ៍សាត់ | 33 | 21 | 144 | 89 | 407 | 271 | 781 | 450 | 981 | 529 |
| 9 | បាត់ដំបង | 77 | 44 | 354 | 223 | 1059 | 680 | 2090 | 1302 | 2578 | 1392 |
| 10 | ប៉ៃលិន | 4 | 2 | 18 | 12 | 86 | 54 | 197 | 121 | 198 | 102 |
| 11 | បន្ទាយមានជ័យ | 82 | 43 | 331 | 207 | 646 | 435 | 1418 | 871 | 1666 | 949 |
| 12 | ឧត្តរមានជ័យ | 6 | 5 | 43 | 29 | 236 | 160 | 579 | 318 | 510 | 258 |
| 13 | សៀមរាប | 188 | 103 | 646 | 407 | 1742 | 1146 | 3094 | 1903 | 2963 | 1655 |
| 14 | កំពង់ធំ | 21 | 8 | 256 | 145 | 876 | 572 | 1710 | 1026 | 1752 | 937 |
| 15 | ព្រះវិហារ | 3 | 1 | 60 | 31 | 320 | 191 | 588 | 337 | 588 | 294 |
| 16 | ស្ទឹងត្រែង | 3 | 1 | 25 | 13 | 124 | 81 | 311 | 178 | 335 | 160 |
| 17 | រតនគិរី | 10 | 5 | 42 | 20 | 232 | 135 | 586 | 334 | 523 | 251 |
| 18 | ក្រចេះ | 35 | 26 | 137 | 90 | 300 | 187 | 570 | 358 | 613 | 337 |
| 19 | ស្វាយរៀង | 16 | 6 | 183 | 108 | 530 | 320 | 1105 | 635 | 1171 | 618 |
| 20 | ព្រៃវែង | 89 | 56 | 501 | 279 | 1371 | 882 | 2197 | 1309 | 2115 | 1110 |
| 21 | កំពង់ចាម | 103 | 58 | 466 | 279 | 1097 | 717 | 2108 | 1303 | 2498 | 1380 |
| 22 | ត្បូងឃ្មុំ | 55 | 38 | 239 | 153 | 723 | 443 | 1418 | 883 | 1635 | 909 |
| 23 | ភ្នំពេញ | 547 | 296 | 1495 | 856 | 2846 | 1672 | 4994 | 2750 | 6187 | 2977 |
| 24 | កំពង់ស្ពឺ | 17 | 11 | 181 | 118 | 684 | 441 | 1410 | 861 | 1469 | 717 |
| 25 | មណ្ឌលគិរី | 0 | 0 | 34 | 24 | 164 | 108 | 262 | 148 | 128 | 74 |
| | **សរុប** | 1,677 | **952** | 6,969 | **4,170** | 18,321 | **11,524** | 34,263 | **19,928** | 37,284 | **19,544** |

*( ប្រភព៖ មន្ទីរកិច្ចការនារី រាជធានី/ខេត្ត)*

# ទស្សនៈយល់ដឹង ក្រោមមូលបទ



លោកស្រី **ឆាន់ ចន្ទសោភា** នាយិការងវិទ្យាល័យសម្តេចឪ ខេត្តបន្ទាយមានជ័យ ដើម្បីចូលរួមអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ២០២៤ក្រោមមូលបទ ***«ស្ត្រី និងក្មេងស្រីក្នុងបរិវត្ត កម្មឌីជីថល»***។ ខ្ញុំយល់ឃើញថា នាពេលបច្ចុប្បនេះ ប្រព័ន្ធបច្ចេក-វិទ្យាកាន់តែទំនើបវិវត្តន៍ទៅមុខឥតឈប់ឈរ ដូច្នេះការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងការអភិវឌ្ឍន្ទូវចំណេះដឹងថ្មីៗទាក់ទងនឹងឌីជីថល មានភាពងាយស្រួលក្នុងការទំនាក់ទំនងការធ្វើអាជីវកម្មផ្សេងៗ ដូចជា ការគ្រប់គ្រងផែនការអាជីវកម្ម ការធ្វើហិរញ្ញវត្ថុ ការបង្កើតមាតិកាក្នុងការចែករំលែកព័ត៌មាន និងការកំសាន្ត ផ្សព្វផ្សាយអាហារ ទេសចរណ៍ វប្បធម៌តាមអនឡាញ ជាដើម។ ទន្ទឹមនឹងនោះ ស្របពេលដែលប្រព័ន្ធឌីជីថលមានការរីកចម្រើន ការប្រើប្រាស់មិនចំគោលដៅ នាំឱ្យមានផលប៉ះពាល់ដល់ស្ត្រី និងក្មេងស្រីផងដែរ ដូចជា ការចាញ់បោកជនខិលខូច...។

នាងខ្ញុំសូមសំណូមពរដល់អាណាព្យាបាលទាំងអស់ ត្រូវបញ្ជូនកូនទៅរៀន ជាពិសេសកូនស្រី ដើម្បីឱ្យពួកគាត់មានចំណេះដឹងសមត្ថភាពផ្នែកឌីជីថល ដើម្បីចាប់យកទីផ្សារ និងបង្កើនប្រាក់ចំណូលកាន់តែច្រើន ដើម្បីបម្រើឱ្យកិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលនៅកម្ពុជា ស្របតាមការរស់នៅរបស់សង្គមឌីជីថលជំនាន់ថ្មី ។



លោក **តាំង សេងឡុក** អនុប្រធានការិយាល័យព័ត៌មាន នៃមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ បានចែករំលែកជាមតិយោបល់ថា៖ ស្ត្រី និងក្មេងស្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមបរិវត្តកម្មឌីជីថល ក្នុងការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ខ្លួន និងគ្រួសារ រួមទាំងការទទួលបានលទ្ធភាពកាន់តែទូលំទូលាយសម្រាប់ការសិក្សាអប់រំ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ការប្រកបមុខរបរការងារ និងអាជីវកម្មជាដើម។ នៅក្នុងនោះ បច្ចេកវិទ្យាឌីជីថល នឹងពង្រីកលទ្ធភាពរបស់ស្ត្រី និងក្មេងស្រី ក្នុងការទទួលបានព័ត៌មាន ចំណេះដឹង ការលើកកម្ពស់សុខុមាលភាព ការបញ្ចេញមតិយោបល់ និងសម្រាប់ការតភ្ជាប់ បណ្តាញទំនាក់ទំនងនៅក្នុងសង្គមកាន់តែទូលំទូលាយ។ ដូចច្នេះស្ត្រី និងក្មេងស្រី ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមក្នុងបរិវត្តកម្មឌីជីថល។



កញ្ញា **សឿន សុទ្ធនីតា** ឬគេហៅថា Ms. Cashew ជាសហស្ថាបនិកទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ពាណិកម្មនៅក្រុមហ៊ុន ហ៊ែនក្រាហ្វធីត យៃស៊ូ ណាត់ ស្ទឹងត្រែង។ ...តាមយោបល់នាងខ្ញុំផ្ទាល់យល់ឃើញថា បច្ចុប្បន្នការប្រើប្រាស់ឌីជីថលពិតជាមានសារៈសំខាន់ណាស់សម្រាប់ស្ត្រី និងក្មេងស្រី ពិសេស សម្រាប់ការធ្វើអាជីវកម្មរបស់ពួកគេជាប្រចាំថ្ងៃ ដែលជាប្រយោជន៍អាចឱ្យគេស្វែងយល់បានស៊ីជម្រៅអំពីតម្រូវការរបស់អតិថិជន និងទីផ្សារ។ មិនតែប៉ុណ្ណោះពួកគេអាចមានឱកាសបានបង្ហាញមុខទំនិញ ឬអាជីវកម្មរបស់ខ្លួនឱ្យពិភពលោកបានស្គាល់ មិនថាក្នុង ឬក្រៅប្រទេសនោះទេ ពួកគេមិនចាំបាច់ទៅជួបដៃគូផ្ទាល់ គឺគ្រាន់តែពួកគេប្រើប្រាស់បច្ចេកវិទ្យាឌីធីថលដូចជា (Telegram Facebook Instargram Website... ) ពួកគេអាចទទួលបានការទំនាក់ទំនង និងព័ត៌មាននានាជាក់លាក់តាមអ្វីដែលគេចង់បាន ដោយមិនបាច់ចំណាយពេលវេលា និងថវិកាច្រើនឡើយ។ ជាពិសេសស្ត្រី និងក្មេងស្រី *«ចូរកុំគិតថាស្ត្រីមិនអាចធ្វើអ្វីបាន ស្ត្រីនិងបុរសគឺអាចធ្វើ អ្វីៗបានដូចគ្នាឱ្យតែយើងមានចិត្តស្រឡាញ់ មោះមុត តស៊ូ និងជំនះរាល់ឧបសគ្គ បើមានឱកាសត្រូវតែចេះចាប់យក ឱកាសនោះទើប យើងអាចដើរឆ្ពោះទៅមុខបាន»*៕

# « ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល »



លោក **ហ៊ត ពីន** ជាប្រធានការិយាល័យសមភាពយេនឌ័រ និងព័ត៌មាន នៃមន្ទីរកិច្ចការនារី ខេត្តស្ទឹងត្រែង។

...ខ្ញុំគិតថាប្រព័ន្ធឌីជីថលគឺមានសារៈសំខាន់ណាស់។ពីមុនការប្រឹក្សាយោបល់ជាមួយជនរងគ្រោះគឺមានភាពពិបាក ហើយការជួបជាមួយជនរងគ្រោះដោយផ្ទាល់គឺគាត់មានការខ្មាស់អៀន និងមិនអាចទទួលព័ត៌មានបានពេញលេញ តែពេលនេះទាំងការទំនាក់ទំនងនិងការស្វែងរកសេវាជំនួយផ្សេងៗមកកាន់មន្ទីរកិច្ចការនារីគឺមានភាពងាយស្រួលតាមរយៈប្រព័ន្ធអនឡាញ ព្រមទាំងអាចទទួលបាននូវព័ត៌មានពេញលេញពីជនរងគ្រោះផងដែរ ។ ម្យ៉ាងវិញទៀត ប្រព័ន្ធអនឡាញបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន ជាពិសេសអំពីការបណ្តុះបណ្តាលជំនាញរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី និងព័ត៌មានអំពីសេវាផ្សេងៗរបស់មន្ទីរកិច្ចការនារីផងដែរ។ ពីមុនប្រសិនជាយើងធ្វើទៅលើ៥ក្រុមគោលដៅគឺទទួលព័ត៌មាន បានតែ៥ក្រុមគោលដៅប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នតាមរយៈប្រព័ន្ធបច្ចេកវិទ្យាគឺមានភាពទូលំទូលាយ ហើយសិស្សនៅមជ្ឈមណ្ឌលយើងក៏អាចស្វ័យសិក្សាបន្ថែមលើជំនាញរបស់គាត់តាមប្រព័ន្ធអនឡាញផងដែរ ។



លោក វរៈសេនីយ៍ទោ **គៀន តេយ** នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង។

...បច្ចុប្បន្នស្ត្រី និងក្មេងស្រីពិតជាទទួលបានឱកាសក្នុងការទទួលបាននូវផលប្រយោជន៍ជាច្រើនពីបច្ចេកវិទ្យាឌីជីថល មិនថាលើការសិក្សា ការប្រាស្រ័យទាក់ទងគ្នា និងការប្រកបរបររកស៊ីទេ ដែលនេះគឺស្របទៅនឹងគោលនយោបាយជាតិ និងសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល ។ ស្របគ្នានេះដែរ ក្នុងនាមខ្ញុំជាមន្ត្រីនគរបាលមួយរូប សូមអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ ជាពិសេសស្ត្រី និងក្មេងស្រីមេត្តាប្រើប្រាស់បច្ចេកវិទ្យាឱ្យបានត្រឹមត្រូវ ជៀសវាងត្រូវបានគេបោកប្រាស់ និងក្លាយខ្លួនទៅជាជនរងគ្រោះលើប្រព័ន្ធអនឡាញផងដែរ។ ប្រសិនបើបងប្អូន ជាពិសេសស្ត្រី និងក្មេងស្រីដែលដឹងថាខ្លួនត្រូវបានគេបោកប្រាស់ ឬធ្លាក់ខ្លួនជាជនរងគ្រោះលើប្រព័ន្ធអនឡាញ សូមមេត្តាប្រញាប់ទំនាក់ទំនងមកសមត្ថកិច្ច ដើម្បីសមត្ថកិច្ចធ្វើការជួយអន្តរាគមន៍ទាន់ពេលវេលា ។



លោកស្រី **មុត ចរិយា** ស្ត្រីលេចធ្លោក្នុងវិស័យកសិឧស្សាហកម្ម កែច្នៃគ្រាប់ស្វាយចន្ទីនៅខេត្តស្ទឹងត្រែង។

...តាមទស្សនៈរបស់ខ្ញុំយល់ឃើញថា ការប្រើប្រាស់ឌីជីថលពិតជាត្រឹមត្រូវណាស់ បច្ចុប្បន្ននេះប្រសិនបើយើង ពិសេសស្ត្រី និងក្មេងស្រី ចង់ធ្វើពាណិជ្ជកម្មណាមួយ ដែលមិនប្រើឌីជីថលទេ នោះគឺយើងដើរមិនទាន់គេទេ ថាតើគេដើរដល់យុគ្គសម័យណាហើយដល់ទីណាហើយ គេត្រូវការអ្វីខ្លះ? ដូច្នេះហើយ នៅក្នុងមូលបទ« *ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល*» ស្ត្រី និងក្មេងស្រីត្រូវតែពូកែ និងរៀនឱ្យបានខ្លាំងពីឌីជីថល ដើម្បីយកមកប្រើប្រាស់ជាប្រយោជន៍សម្រាប់ខ្លួនឯង និងសង្គមជាតិ។

ជាចុងក្រោយខ្ញុំសូមផ្តាំផ្ញើទៅដល់ស្ត្រី និងក្មេងស្រីគ្រប់រូបថា « *គ្រប់ការងារទាំងអស់មិនមែនស្ត្រីធ្វើមិនបាននោះទេ គ្មានការងារណាដែលថាស្ត្រីធ្វើមិនបានទេ បើយើងមានឆន្ទៈធ្វើ នោះយើងនឹងធ្វើការងារមួយហ្នឹងបានដោយជោគជ័យ*»។

# សម្ព័ន្ធភាពរវាងនារី និងកងទ័ព



**សម្ព័ន្ធភាពរវាងនារី  និងកងទ័ពតំបន់ប្រតិបត្តិការសឹងរងទី១ ទី២ និងទី៣ នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តស្ទឹងត្រែង**

លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានដឹកនាំគណៈប្រតិភូក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីទាំង២៥រាជធានី-ខេត្ត ចុះសួរសុខទុក្ខកងទ័ពវរសេនាតូចលេខ២ តំបន់ប្រតិបត្តិការសឹងរងខេត្តរតនគិរី យោធភូមិភាគទី១ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ ។

លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីបានមានប្រសាសន៍ថា៖ ដើម្បីអនុវត្តនូវអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចងសម្ព័ន្ធមេត្រីភាពជាមួយកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ក្រសួងកិច្ចការនារី បានចងសម្ព័ន្ធមេត្រីភាពរវាងតំបន់សឹករងទី១ ទី២ និងទី៣ ដែលស្ថិតនៅក្នុងខេត្តរតនគិរី មណ្ឌលគិរី និងខេត្តស្ទឹងត្រែង។ ទន្ទឹមនឹងនេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក៏មិនភ្លេចអរគុណសន្តិភាព អរគុណគោលនយោបាយឈ្នះឈ្នះ និងអរគុណ**សម្តេចតេជោ**អតីតនាយករដ្ឋមន្ត្រីដែលជាអគ្គមគ្គុទ្ទេសន៍ផ្តើមក្នុងការកសាងសុខសន្តិភាព និងការពារបូរណភាពទឹកដីផងដែរ។

លោកមេបញ្ជាការវរសេនាតូចលេខ២ តំបន់សឹករងរតនគិរី យោធភូមិភាគទី១ បានលើកឡើងថា៖ ការចងសម្ព័ន្ធមេត្រីភាពរវាងក្រសួងកិច្ចការនារី និងដៃគូក្រុមហ៊ុនមួយចំនួន ជាមួយវរសេនាតូចលេខ២ តំបន់សឹងរងខេត្តរតនគិរី បានផ្តល់ផ្លែផ្កាយ៉ាងច្រើនគួរឱ្យកត់សម្គាល់ដូចជា ជំរុំជម្រកមធ្យោបាយ សម្ភារៈ ស្បៀងអាហារ និងថវិកាមួយចំនួន







ទៀត។ កាយវិការដ៏ល្អប្រពៃថ្លៃថ្លាទាំងនេះ គឺជាការគិតគូរយកចិត្តទុកដាក់របស់លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ដើម្បីរួមចំណែកក្នុងការដោះស្រាយជីវភាព រស់នៅរបស់កងទ័ពឱ្យកាន់តែមានភាពរីកចម្រើនមួយកម្រិតថែមទៀត សំដៅពង្រឹងគុណភាពកងទ័ពឱ្យស្របតាមគោលនយោបាយបញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា ដែលដឹកនាំដោយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

លោកមេបញ្ជាការវរសេនាតូចលេខ២ បានកោតសរសើរ និងវាយតម្លៃខ្ពស់នូវការជួយឧបត្ថម្ភគាំទ្រជាសម្ភារៈ ថវិកាដ៏ថ្លៃថ្លារយៈពេលកន្លងមក ក៏ដូចជានាពេលនេះ ពិតជាបង្ហាញឱ្យឃើញនូវស្មារតីសាមគ្គីភាព រវាងស្ថាប័នស៊ីវិល និងកងទ័ពកាន់តែរឹងមាំគ្រប់កាលៈទេសៈ សំដៅពង្រឹងខឿនការពារជាតិមាតុភូមិឱ្យក្លាយជាព្រំដែនសន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ព្រំដែន។

លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីបានមានប្រសាសន៍បន្តទៀតថា៖ កងទ័ពមានតួនាទីសំខាន់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសក្នុងតំបន់អាស៊ាន ដោយរួមគ្នាថែរក្សា ការពារ ទឹកដី ព្រំដែន ការពារសន្តិភាព មិត្តភាព និងរួមគ្នាអភិវឌ្ឍន៍ព្រំដែន ដើម្បីចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន (វៀតណាម ឡាវ កម្ពុជា)៕



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
ក្រុមការងារយេនឌ័រ

# តារាងស្ថិតិមន្ត្រីរាជការស៊ីវិលសរុប នៅតាមក្រសួង-ស្ថាប័ននានា ឆ្នាំ២០២២

| ល.រ | ក្រសួង-ស្ថាប័ន | ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ | | | ចំនួនមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិ | | | ចំនួនមន្ត្រីរាជការស៊ីវិលសរុប | | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | សរុបរួម | ស្រី | ស្រី | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | 1,074 | 324 | 1,398 | 0 | 0 | 0 | 1,398 | 324 | 23% | |
| ២ | ព្រះបរមរាជវាំង | 311 | 67 | 378 | 0 | 0 | 0 | 378 | 67 | 18% | |
| ៣ | មហាផ្ទៃ | 1,835 | 484 | 2,319 | 26,172 | 20,253 | 46,425 | 48,744 | 20,737 | 43% | |
| ៤ | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 492 | 250 | 742 | 0 | 0 | 0 | 742 | 250 | 34% | |
| ៥ | អភិវឌ្ឍន៍ជនបទ | 449 | 194 | 643 | 634 | 214 | 848 | 1,491 | 408 | 27% | |
| ៦ | ពាណិជ្ជកម្ម | 968 | 367 | 1,335 | 260 | 155 | 415 | 1,750 | 522 | 30% | |
| ៧ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 4,450 | 1,841 | 6,291 | 350 | 244 | 594 | 6,885 | 2,085 | 30% | |
| ៨ | អប់រំ យុវជន និងកីឡា | 3,351 | 1,764 | 5,115 | 63,033 | 57,414 | 120,447 | 125,562 | 59,178 | 47% | |
| ៩ | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 295 | 149 | 444 | 252 | 117 | 369 | 813 | 266 | 33% | |
| ១០ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 581 | 169 | 750 | 1,018 | 251 | 1,269 | 2,019 | 420 | 21% | |
| ១១ | ផែនការ | 624 | 343 | 967 | 765 | 618 | 1,383 | 2,350 | 961 | 41% | |
| ១២ | ធម្មការ និងសាសនា | 350 | 94 | 444 | 649 | 158 | 807 | 1,251 | 252 | 20% | |
| ១៣ | បរិស្ថាន | 719 | 239 | 958 | 1,513 | 139 | 1,652 | 2,610 | 378 | 14% | |
| ១៤ | យុត្តិធម៌ | 314 | 171 | 485 | 1,703 | 681 | 2,384 | 2,869 | 852 | 30% | |
| ១៥ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | 626 | 267 | 893 | 224 | 119 | 343 | 1,236 | 386 | 31% | |
| ១៦ | ព័ត៌មាន | 687 | 372 | 1,059 | 315 | 217 | 532 | 1,591 | 589 | 37% | |
| ១៧ | វប្បធម៌ និងវិចិត្រសិល្បៈ | 1,204 | 652 | 1,856 | 434 | 304 | 738 | 2,594 | 956 | 37% | |
| ១៨ | ទេសចរណ៍ | 450 | 224 | 674 | 315 | 190 | 505 | 1,179 | 414 | 35% | |
| ១៩ | សុខាភិបាល | 2,954 | 3,081 | 6,035 | 0 | 0 | 0 | 6,035 | 3,081 | 51% | |
| ២០ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 2,513 | 938 | 3,451 | 808 | 303 | 1,111 | 4,562 | 1,241 | 27% | |
| ២១ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 586 | 383 | 969 | 464 | 344 | 808 | 1,777 | 727 | 41% | |
| ២២ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 2,131 | 867 | 2,998 | 2,306 | 602 | 2,908 | 5,906 | 1,469 | 25% | |
| ២៣ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | 502 | 192 | 694 | 357 | 129 | 486 | 1,180 | 321 | 27% | |
| ២៤ | រ៉ែ និងថាមពល | 392 | 120 | 512 | 281 | 66 | 347 | 859 | 186 | 22% | |
| ២៥ | សាធារណការ និងដឹកជញ្ជូន | 1,245 | 291 | 1,536 | 1,108 | 335 | 1,443 | 2,979 | 626 | 21% | |
| ២៦ | កិច្ចការនារី | 62 | 170 | 232 | 86 | 356 | 442 | 674 | 526 | 78% | |
| ២៧ | ធនធានទឹក និងឧតុនិយម | 654 | 202 | 856 | 417 | 105 | 522 | 1,378 | 307 | 22% | |
| ២៨ | មុខងារសាធារណៈ | 553 | 254 | 807 | 269 | 171 | 440 | 1,247 | 425 | 34% | |
| ២៩ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 551 | 200 | 751 | 0 | 0 | 0 | 751 | 200 | 27% | |
| ៣០ | អង្គភាពប្រឆាំងអំពើពុករលួយ | 328 | 168 | 496 | 0 | 0 | 0 | 496 | 168 | 34% | |
| | សរុប គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | *31,251* | *14,837* | *46,088* | *103,733* | *83,485* | *187,218* | *233,306* | *98,322* | | |
| | គិតជាភាគរយ (%) | 68% | 32% | 100% | 55% | 45% | 100% | 100% | 42% | | |

បានឃើញ និងឯកភាព
ថ្ងៃ... ខែ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី... ខែឧសភា ឆ្នាំ២០២៣
រដ្ឋមន្ត្រី

ហ៊ុំ-សុខា

ថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣
ប្រធានក្រុមការងារយេនឌ័រ

ឈី ចិន្តា




ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

## សេចក្តីថ្លែងអំណរគុណ

ក្រសួងកិច្ចការនារី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងសប្បុរសជនទាំងអស់ ដែលបានជួយឧបត្ថម្ភគាំទ្រ ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣

*The Ministry of Women's Affairs would like to express its profound thanks to the Royal Government of Cambodia and the following donors who have sponsored the program to mark the 113th International Women's Day, 8th March 2024.*

Embassy of the People's Republic of China in the Kingdom of Cambodia
Australian Aid
ACCESS 2 Sustainable quality services for all
The Fred Hollows Foundation
The Asia Foundation
CANADIA BANK
OXFAM
UNDP
unesco
unicef unite for children
UNFPA
PLAN INTERNATIONAL
Kino
REVLON
pact building local promise.
GADC
RECOFTC
WaterAid
care
COMFREL

**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី**

ផ្លូវទ្រុងមាន់ ត្រូវដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

Department of Information, Ministry of Women's Affairs

Street Trung Morn, Domnak Thom III, Stoeung Meanchey, Khan Meanchey, Phnom Penh